ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សទ្ទានុក្រមពាក្យច្បាប់

## ខ្មែរ~អង់គ្លេស~បារាំង

## ផ្នែក

# រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី

## LEXICON OF LEGAL TERMS
## LEXIQUE DES TERMES JURIDIQUES
## Khmer-English-French

## ទីស្តីការគណៈរដ្ឋមន្ត្រី

គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

បោះពុម្ពលើកទី១

ឆ្នាំ២០០៧

# សទ្ទានុក្រម
# ផ្នែករដ្ឋប្បវេណី

ដកស្រង់ពី

**"សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី"**

ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

និង បោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ ២០០៧

# ក

១. **កម្មិកសមាជិក**
Eng. **a**ctive member
Fr. **m**embre actif

១-តាមន័យទូទៅ ៖ សមាជិក ដែលស្ម័គ្រចិត្ត ចូលបំពេញមុខងារក្នុងសមាគមណាមួយដោយ កម្លាំងកាយ ឬទ្រព្យសម្បត្តិ ឬក៏ទាំងពីរ ។
២-តាមក្រមរដ្ឋប្បវេណី មានន័យថា បុគ្គលដែលមានសិទ្ធិអំណាចក្នុងការអនុវត្ត និងគ្រប់គ្រងកិច្ចការរបស់នីតិបុគ្គល ។

២. **កម្រៃជើងសារ**
Eng. **c**ommission
Fr. **c**ommission

កម្រៃ ដែលផ្ដល់ទៅឱ្យបុគ្គលដែលបានបំពេញសកម្មភាព តាមកិច្ចសន្យាអាណត្តិ ។

៣. **ករណីយកិច្ចផ្ដាច់មុខ**
Eng. **e**xclusive duty
Fr. **d**evoir exclusif

ករណីយកិច្ច ដែលផ្សារភ្ជាប់នឹងបុគ្គលិកលក្ខណៈ របស់បុគ្គលណាមួយ ដែលមិនអាចត្រូវបានផ្ទេរ តាមរយៈសន្តតិកម្ម ។
ឧ. កូនមានករណីយកិច្ចចិញ្ចឹមឪពុកម្ដាយ នៅពេលដែលឪពុកម្ដាយចាស់ជរា ។ នៅពេលដែលកូននេះស្លាប់ ករណីយកិច្ចនេះមិនត្រូវបានផ្ទេរទៅសន្តតិជនរបស់កូននោះឡើយ ។

៤. **កាតព្វកិច្ច**
Eng. **o**bligation
Fr. **o**bligation

ចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា "កូនបំណុល" មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ហៅថា "ម្ចាស់បំណុល" ។

៥. **កាតព្វកិច្ចចម្បង**
Eng. **u**nderlying obligation / **p**rincipal obligation
Fr. **o**bligation principale

កាតព្វកិច្ចដើមនៃកិច្ចសន្យា ដែលបង្កើតឡើង ដោយម្ចាស់បំណុល និងកូនបំណុល ។

៦. **កាតព្វកិច្ចដោយសាមគ្គីភាព**
Eng. **j**oint obligation
Fr. **o**bligation solidaire

កាតព្វកិច្ចរបស់កូនបំណុលច្រើននាក់ ដែលក្នុងនោះកូនបំណុលម្នាក់ៗ ឬច្រើននាក់ត្រូវអនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់តាមការទាមទាររបស់ម្ចាស់បំណុល ។

៧. **កាតព្វកិច្ចធានា**
Eng. **g**uaranty obligation
Fr. **o**bligation de garantie

ករណីយកិច្ចរបស់អ្នកធានា ដែលត្រូវអនុវត្តកាតព្វកិច្ចមួយផ្នែក ឬទាំងមូលជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បងនៅក្នុងករណីដែលកូនបំណុល មានកាតព្វកិច្ចចម្បងនោះ មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។

៨. **កាតព្វកិច្ចអនិយ័ត**
Eng. **c**hoice of obligation
Fr. **o**bligation alternative

កាតព្វកិច្ច ដែលផ្ដល់ឱ្យកូនបំណុលនូវលទ្ធភាព ក្នុងការជ្រើសរើសកាតព្វកិច្ចតែមួយ ឬច្រើនក្នុងចំណោមការផ្ដល់កម្មវត្ថុនៃកាតព្វកិច្ចច្រើនប្រភេទ ។

៩. **ការការពារជាធម្មានុរូប**
Eng. **s**elf-defence
Fr. **l**égitime defense

អំពើតបត ដែលបង្កឱ្យមានអន្តរាយដោយពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃចំពោះអំពើ

បំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និងអំពើតបតកើតឡើងដំណាលគ្នា និងមានសមាមាត្ររវាងវិធីការពារ និងកម្រិតនៃអំពើបំពាននោះ ។

១០. **ការប្រាក់សមាស**
Eng. **c**ompound interests
Fr. **i**ntérêts composés

ការប្រាក់ ដែលបូកបញ្ចូលទៅក្នុងប្រាក់ដើមបាន ក្នុងករណីដែលកូនបំណុលមានការយឺតយ៉ាវ មិនបានបង់ប្រាក់សម្រាប់រយៈពេលចាប់ពី ០១ឆ្នាំឡើងទៅ ទោះបីជាម្ចាស់បំណុលបានដាស់តឿន ឱ្យសងក៏ដោយ ។

១១. **ការព្រមព្រៀងដោយតុណ្ហីភាព**
Eng. **t**acit agreement
Fr. **a**ccord tacite

សកម្មភាពបង្ហាញឆន្ទៈដោយស្ងៀមស្ងាត់ ដោយគ្មានការសរសេរ ឬការថ្លែងជាក់លាក់ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ។

១២. **ការសន្យាពិសេស**
Eng. **s**pecial clause
Fr. **c**lause spéciale

ការព្រមព្រៀងគ្នា រវាងគូភាគីស្របតាមបញ្ញត្តិ លើកលែងដែលមានចែងក្នុងច្បាប់ ហើយបង្កើតអានុភាពតាមផ្លូវច្បាប់ ។

១៣. **ការរ្យ**
Eng. **w**orkmanship
Fr. **o**uvrage

ផលអ្វីទាំងពួង ដែលកើតមកពីស្នាដៃជាង ឬ ស្នាដៃសិល្បករ ។ល ។

១៤. **កាលបរិច្ឆេទស្ថាពរ**
Eng. **d**ue date
Fr. **d**élai de rigueur

ពេលវេលាកំណត់ជាក់លាក់ទុកជាបានការ ដែលភាគីមិនអាចកែប្រែនៅពេលក្រោយបាន ។

១៥. **កិច្ចសន្យា**
Eng. **c**ontract
Fr. **c**ontrat

កិរិយា ដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈ ត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច ។

១៦. **កិច្ចសន្យាធនលាភសាមយិកមួយជីវិត**
Eng. **l**ife annuity contract
Fr. **c**ontrat de rente viagère

កិច្ចសន្យាមួយ ដែលភាគីម្ខាងជាកូនបំណុលនៃធនលាភ សន្យាថា មានករណីយកិច្ចត្រូវផ្តល់តាវកាលិកជាប្រាក់ តាមពេលកំណត់ទៀងទាត់ ទៅឱ្យភាគីម្ខាងទៀត ដែលជាម្ចាស់បំណុល ឬ តតិយជននៃធនលាភ រហូតដល់ពេលដែលខ្លួនផ្ទាល់ ឬភាគីម្ខាងទៀត ឬក៏តតិយជនបានទទួលមរណភាព ហើយភាគីម្ខាងទៀតសន្យាថា មានករណីយកិច្ចទទួលបន្ទុកផ្តល់តាវកាលិក ដែលជាតម្លៃថ្នូរនោះ ។

១៧. **កិច្ចសន្យាបញ្ញើ**
Eng. **b**ailment
Fr. **c**ontrat de dépôt

កិច្ចសន្យា ដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើពីភាគីម្ខាងទៀត ជាអ្នកផ្ញើមករក្សាទុក ក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយអំឡុងពេលរក្សាទុកនោះ ត្រូវបានបញ្ចប់ ត្រូវសងវត្ថុនោះទៅឱ្យអ្នកផ្ញើវិញ ដោយយកកម្រៃ ឬមិនយកកម្រៃ ។

១៨. **កិច្ចសន្យាប្រវាស់**
Eng. **r**ent-leasehold
Fr. **c**ontrat de fermage

កិច្ចសន្យា ដែលកម្មសិទ្ធិករឱ្យភតិកៈខ្ចីដី ឬសត្វពាហនៈដើម្បីទាញយកផល ហើយយកផលនោះ មកបែងចែកគ្នា។

១៩. **កិច្ចសន្យាមជ្ឈត្តកម្ម**
Eng. **a**rbitration agreement
Fr. **c**ompromis d'arbitrage

កិច្ចសន្យា ដែលធ្វើឡើងដោយភាគីនៃវិវាទ ដើម្បីជ្រើសរើសតតិយជនណាម្នាក់ ឱ្យធ្វើជាមជ្ឈត្តករ ដើម្បីដោះស្រាយវិវាទ។

២០. **កិច្ចសន្យាម៉ៅការ**
Eng. **w**orks contract
Fr. **c**ontrat de louage d'ouvrage / **c**ontrat d'entreprise

កិច្ចសន្យាមួយ ដែលភាគីម្ខាងមានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀត មានករណីយកិច្ចផ្ដល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ។

២១. **កិច្ចសន្យាអញ្ញមញ្ញ**
Eng. **s**ynallagmatical contract
Fr. **c**ontrat synallagmatique

កិច្ចសន្យា ដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមកដូចជា កិច្ចសន្យាម៉ៅការ ភតិសន្យា កិច្ចសន្យាលក់ទំនិញ...។

២២. **កិច្ចសន្យាអាណត្តិ**
Eng. **m**andate
Fr. **m**andat

កិច្ចសន្យាមួយ ដែលអាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យទៅអាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក។

២៣. **កូរ៉ុម**
Eng. **q**uorum
Fr. **q**uorum

១-ចំនួនវត្តមានចាំបាច់នៃសមាជិក ដែលមានសិទ្ធិសម្រេចដើម្បីឱ្យការប្រជុំ ឬមហាសន្និបាត របស់នីតិបុគ្គលមានសុពលភាព។
២-តាមក្រមរដ្ឋប្បវេណី មានន័យថា ចំនួនចាំបាច់នៃសមាជិក ដែលមានសិទ្ធិសម្រេចចាប់ពី១/១០ ឡើងទៅនៃចំនួនសមាជិកទាំងអស់ ដែលមានសិទ្ធិសម្រេច ដើម្បីទាមទារឱ្យបើកមហាសន្និបាត របស់នីតិបុគ្គល។

២៤. **កូនបំណុលដែលមានកាតព្វកិច្ចចម្បង**
Eng. **d**ebtor of the principal obligation
Fr. **d**ébiteur principal / **d**ébiteur

កូនបំណុល ដែលត្រូវអនុវត្តកាតព្វកិច្ចដើម ហើយកាតព្វកិច្ចនោះត្រូវបានធានាដោយកិច្ចសន្យាធានា។

២៥. **កើយ**
Eng. **b**alcony
Fr. **b**alcon

យ៉ ឬរានហាលតូចគ្មានសសរទ្រពីក្រោមទេ តែមានបង្កាន់ដៃព័ទ្ធជុំវិញ។

២៦. **កំជាប់ពាក្យ**
Eng. engagement
Fr. **f**iançailles

ពិធីតាមទំនៀមទម្លាប់ប្រពៃណី ដែលច្បាប់ទទួលស្គាល់ ដែលតាមរយៈពិធីនេះ បុរស និងនារីសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។

២៧. **ក្ស័យធន**
Eng. **b**ankruptcy
Fr. **f**aillite

ស្ថានភាព ដែលកូនបំណុលមិនអាចសងកាតព្វកិច្ច ចំពោះម្ចាស់បំណុលទាំងឡាយបាន ដោយសារការដួលរលំនូវសេដ្ឋកិច្ចរបស់ខ្លួន ដែលត្រូវបានប្រកាស ដោយតុលាការ។

# ខ គ

២៨. **ខសន្យា**
Eng. **c**lause
Fr. **c**lause

បទប្បញ្ញត្តិ ឬប្រការ ដែលមានក្នុងកិច្ចសន្យា ។

២៩. **គណនេយ្យ**
Eng. **a**ccounting
Fr. **c**omptabilité

កិច្ចការថែរក្សា គ្រប់គ្រង ឬត្រួតពិនិត្យបញ្ជីគណនី ។

៣០. **គតិយុត្ត**
Eng. **j**uridical
Fr. **j**uridique

-តាមគន្លងច្បាប់
-ដែលទាក់ទងនឹងច្បាប់ ដែលត្រឹមត្រូវតាមច្បាប់ ។

៣១. **គោលការណ៍**
Eng. **p**rinciple
Fr. **p**rincipe

១-វិធានទូទៅ ឬទ្រឹស្តីមួយ ដែលផ្តល់នូវមូលដ្ឋាន ឬប្រភពដើមនៃបទដ្ឋានគតិយុត្ត ។
២-វិធានគតិយុត្ត ដែលបង្កើតដោយអត្ថបទច្បាប់ណាមួយដែលមានលក្ខណៈទូទៅ ក្នុងគោលបំណងធានាការអនុវត្តផ្សេងៗ ហើយមានតម្លៃគតិយុត្តខ្ពស់ ។

៣២. **គ្រោះមហន្តរាយធម្មជាតិ**
Eng. **n**atural disaster
Fr. **c**atastrophe naturelle

ការខូចខាត ដែលបង្កឡើងដោយបាតុភូតធម្មជាតិ ដូចជា ខ្យល់ព្យុះ ទឹកជំនន់ រញ្ជួយដី... ។

# ច ឆ ជ

| | | |
|---|---|---|
| ៣៣. | **ចលនវត្ថុ**<br>Eng. **m**ovable<br>Fr. **m**euble | វត្ថុទាំងឡាយក្រៅពីអចលនវត្ថុ ។<br>( ម.ព. អចលនវត្ថុ ) |
| ៣៤. | **ចារី**<br>Eng. **p**erpetrator<br>Fr. **a**uteur | បុគ្គល ដែលបំពានដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍ជនដទៃ ដោយកំហុសចេតនាក្ដី ឬ អចេតនាក្ដី ។ |
| ៣៥. | **ចុល្លព្រឹក្ស**<br>Eng. **s**hrubs<br>Fr. **a**rbrisseau | សំដៅលើដើមឈើតូចៗ ។ |
| ៣៦. | **ឆន្ទានុសិទ្ធិ**<br>Eng. **d**iscretion<br>Fr. **p**ouvoir discrétionnaire | ១-អំណាច ដែលប្រគល់ឱ្យចៅក្រមរើសយកមធ្យោបាយណាមួយតាមការវាយតម្លៃរបស់ខ្លួន មកដោះស្រាយបញ្ហាណាមួយ ។<br>២-អំណាចរបស់ចៅក្រម ក្នុងការធ្វើសកម្មភាព ក្នុងនីតិវិធីនៃបណ្ដឹង ដោយមិនបាច់មានពាក្យសុំ របស់ភាគី ។ |
| ៣៧. | **ជនដែលមាននិស្ស័យពិសេស**<br>Eng.<br>Fr. | បុគ្គល ដែលមិនមែនជាសន្តតិជន តែមានជីវភាពរស់នៅជាមួយគ្នានឹងមតកជន ឬជាបុគ្គល ដែលបានខិតខំមើលព្យាបាលមតកជនជាអាទិ៍ ។ |
| ៣៨. | **ជម្រះបញ្ជី**<br>Eng. **l**iquidation<br>Fr. **l**iquidation | ប្រតិបត្តិការបឋម ដើម្បីសម្រួលនូវទំនាក់ទំនង ទ្រព្យសម្បត្តិក្នុងករណីដែលនីតិបុគ្គល ឬក្រុមហ៊ុន ត្រូវបានរំលាយ ។ |
| ៣៩. | **ជំនូន**<br>Eng. **b**etrothal<br>Fr. **p**résent / **c**adeau | ព័ស្ដុភារ ឬបណ្ណាការ ដែលភាគីម្ខាងជូនទៅភាគីម្ខាងទៀតក្នុងពិធីភ្ជាប់ពាក្យ ។ |

# ញ ដ ឋ

៤០. **ញាតិ** — ញាតិលោហិតក្នុង៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធ ក្នុង៣ថ្នាក់ ។

Eng. **r**elatives
Fr. **l**ien familial /
**l**ien de famille

៤១. **ញាតិពន្ធ** — ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិត របស់សហព័ទ្ធម្ខាងទៀត (សាច់ថ្លៃ) ។

ឧ. ឪពុកម្តាយក្មេក និងកូនប្រសា បងថ្លៃ ប្អូនថ្លៃ (ខាងប្តី ឬខាងប្រពន្ធ) ។ល។

Eng. **a**ffinity
Fr. **a**lliance

៤២. **ញាតិពន្ធខ្សែផ្ទាល់** — ញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃ ដែលកើតតពីមួយទៅមួយតាមលំដាប់ដូចជា ជីដូនជីតាក្មេក ឪពុក ម្តាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត ។

Eng. **d**irect affinity
Fr. **a**lliance en ligne directe

៤៣. **ញាតិលោហិត** — ញាតិ ដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុក និងកូន ឬម្តាយ និងកូន ជាដើម ។

Eng. **c**onsanguinity
Fr. **p**arenté

៤៤. **ញាតិលោហិតខ្សែផ្ទាល់** — ញាតិ ដែលមានឈាមជ័រជាមួយគ្នា ហើយកើតតគ្នាពីមួយទៅមួយតាមលំដាប់ គឺ ឪពុក ម្តាយ កូន ចៅ ចៅទួត ។

Eng. **d**irect consanguinity
Fr. **p**arenté en ligne directe

៤៥. **ដីបម្រើ** — ដី ដែលជារបស់អ្នកដទៃដែលផ្តល់ផលប្រយោជន៍ ដល់ដីរបស់ជនណាមួយទៀត ។

Eng. **s**ervient land
Fr. **f**onds servant

៤៦. **ដីប្រើ** — ដី ដែលកើតផលប្រយោជន៍ដោយដីបម្រើ ។

Eng. **d**ominant land
Fr. **f**onds dominant

៤៧. **ឋបនីយផ្លូវចិត្ត** — ការបង្ហាញឆន្ទៈដោយភាគី ដែលដឹងខ្លួនថា ខុសពីឆន្ទៈពិតរបស់ខ្លួន ។

Eng. **m**ental reservation
Fr. **r**estriction mentale

# ត

៤៨. **តតិយជន** ជនទីបី ឬជន ដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត។ ជនដែលមិនមែនជាភាគីក្នុងរឿងក្តីរដ្ឋប្បវេណី។

Eng. **t**hird party
Fr. **t**iers

៤៩. **តារាងតុល្យការ** តារាង ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិ (ទ្រព្យអកម្ម និងទ្រព្យសកម្ម) របស់នីតិបុគ្គល។

Eng. **b**alance sheet
Fr. **b**ilan

៥០. **តាវកាលិក** វត្ថុ ឬសកម្មភាព ដែលជាទីតាំង (ឬជាកម្មវត្ថុ) នៃកាតព្វកិច្ច។

ឧ. តាវកាលិករបស់អ្នកទិញ គឺបង់ថ្លៃទៅឱ្យអ្នកលក់ ឯតាវកាលិករបស់អ្នកលក់ គឺប្រគល់វត្ថុ ទៅឱ្យអ្នកទិញ។

ឧ. ស្រូវ ដែលជនម្នាក់ខ្ចីពីជនម្នាក់ទៀត ហៅថា តាវកាលិកនៃការខ្ចី។

Eng. **p**restation
Fr. **p**restation

៥១. **តុណ្ហីភាព** ភាពស្ងៀមស្ងាត់ក្នុងការបង្ហាញឆន្ទៈ។

Eng. **i**mpliedly / **t**acit
Fr. **a**ccord tacite

# ទ

៥២. **ទណ្ឌកម្ម**
Eng. **d**iscipline / **c**orrection
Fr. **p**unition
តាមក្រមរដ្ឋប្បវេណី មានន័យថា សិទ្ធិប្រៀនប្រដៅកូន ក្នុងគោលបំណងអប់រំដោយព្រហ្មវិហារធម៌របស់អ្នកមានអំណាចមេបា ។

៥៣. **ទាយក**
Eng. **d**onor
Fr. **d**onateur
ភាគីម្ខាងនៃកិច្ចសន្យាប្រទានកម្ម ដែលបង្ហាញឆន្ទៈផ្ដល់ទៅឱ្យភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ។

៥៤. **ទីសំណាក់**
Eng. **r**esidence
Fr. **r**ésidence
ទីស្ថាន ដែលបុគ្គលម្នាក់ស្នាក់អាស្រ័យនៅ ឬ អាស្រ័យនៅជាក់ស្ដែង ក្នុងរយៈពេលជាកំណត់ណាមួយដែលមិនមែនជាលំនៅឋាន ។

៥៥. **ទីស្នាក់ការកណ្ដាល**
Eng. **p**rincipal office
Fr. **s**iège social / **é**tablissement principal
ទីតាំង ដែលបញ្ជាក់ក្នុងលក្ខន្តិកៈរបស់នីតិបុគ្គល និងដែលត្រូវកំណត់ថាជាការិយាល័យចម្បងរបស់នីតិបុគ្គល ។

៥៦. **ទីស្នាក់ការសាខា**
Eng. **s**econdary office
Fr. **é**tablissement secondaire
ការិយាល័យនៃនីតិបុគ្គលនានា ដែលជាសាខាធ្វើសកម្មភាពក្រោមការណែនាំ ឬបញ្ជារបស់ទីស្នាក់ការកណ្ដាល ។

៥៧. **ទំនាក់ទំនងគតិយុត្ត**
Eng. **l**egal relationship
Fr. **r**apports juridiques
ចំណងកើតឡើងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ តាមរយៈកិច្ចគតិយុត្ត ឬបញ្ញត្តិច្បាប់ ។

៥៨. **ទ្វេពន្ធភាព**
Eng. **b**igamy
Fr. **b**igamie
ភាពនៃបុគ្គលម្នាក់ ដែលពុំទាន់រំលាយចំណងអាពាហ៍ពិពាហ៍មុនផង ហើយរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ឬភាពមានប្រពន្ធពីរ ឬប្ដីពីរ ។

៥៩. **ទ្រព្យសកម្ម**
Eng. **a**ssets
Fr. **a**ctif
ទ្រព្យសម្បត្តិ ដែលនីតិបុគ្គលមាន ។

៦០. **ទ្រព្យសម្បត្តិជាមូលដ្ឋាន**
Eng. **c**apital
Fr. **c**apital
ចំនួនជាក់លាក់នៃទ្រព្យសម្បត្តិ ដែលនីតិបុគ្គលទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលមូលនិធិ ត្រូវមានតាមការកំណត់របស់ច្បាប់ ។

៦១. **ទ្រព្យសម្បត្តិដោយឡែក**
Eng. **s**eperate property
Fr. **b**iens propres
ទ្រព្យសម្បត្តិ ដែលសហព័ទ្ធម្ខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និងបានទទួលដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ។

៦២. **ទ្រព្យសម្បត្តិរួម**
Eng. **c**ommunity property
Fr. **b**iens communs
ទ្រព្យសម្បត្តិទាំងឡាយ ដែលប្ដីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែក ។

៦៣. **ទ្រព្យសម្បត្តិសកល** ទ្រព្យសម្បត្តិទាំងអស់របស់បុគ្គលណាម្នាក់ រួមមានទ្រព្យសកម្ម និង ទ្រព្យអកម្ម។

Eng. **u**niversal property
Fr. **b**iens universels

# ធ ន

៦៤. **ធនលាភ**
Eng. **a**nnuity
Fr. **r**ente

ផល ដែលទទួលបានមកជាទៀងទាត់ ដូចជា ការប្រាក់ ឈ្នួលដី ឈ្នួលផ្ទះ ជាដើម ។

៦៥. **ធនលាភមួយជីវិត**
Eng. **l**ife annuity
Fr. **r**ente viagère

ធនលាភ ដែលធនលាភីត្រូវបានទទួលអស់មួយជីវិត ។

៦៦. **នត្ថិភាព**
Eng. **n**on-existence
Fr. **i**nexistence

ភាវៈគ្មាន ឬភាពនៃអ្វីៗ ដែលមិនមាន ។

៦៧. **នវកម្ម**
Eng. **n**ovation
Fr. **n**ovation

កិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុល ដែលរំលត់កាតព្វកិច្ចដើម និងបង្កើតកាតព្វកិច្ចថ្មីជំនួសកាតព្វកិច្ចដើមនោះ ។

៦៨. **និយោជក**
Eng. **e**mployer
Fr. **e**mployeur

ភាគីម្ខាងនៃកិច្ចសន្យាការងារ ដែលសន្យាផ្ដល់ប្រាក់ឈ្នួលទៅលើកិច្ចការពលកម្មរបស់ភាគីម្ខាងទៀត (និយោជិត) ។

៦៩. **និយោជិត**
Eng. **e**mployee
Fr. **e**mployé

ភាគីម្ខាងនៃកិច្ចសន្យាការងារ ដែលសន្យាធ្វើពលកម្មឱ្យភាគីម្ខាងទៀត (និយោជក) ។

៧០. **នីតិជន**
Eng. **a**dult
Fr. **m**ajeur

១-តាមន័យទូទៅ : បុគ្គល ដែលមានអាយុគ្រប់ តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ ។
២-តាមក្រមរដ្ឋប្បវេណី មានន័យថា ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ។

៧១. **នីតិបុគ្គល**
Eng. **j**uridical person / **l**egal person / **a**rtificial person
Fr. **p**ersonne morale

ក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច ។
ឧ. សមាគម ក្រុមហ៊ុន ។ល ។

៧២. **នីតិបុគ្គលមូលនិធិ**
Eng. **i**ncorporated foundation
Fr. **f**ondation

បណ្ដុំនៃទ្រព្យសម្បត្តិវិភាគទាន ដែលត្រូវបានផ្ដល់នូវសិទ្ធិ និងកាតព្វកិច្ច ។

៧៣. **នីតិបុគ្គលយកចំណេញ**
Eng. **f**or-profit juridical person
Fr. **p**ersonne morale à but lucratif

នីតិបុគ្គល ដែលធ្វើសកម្មភាពស្វែងរកចំណេញ ។

៧៤. **នីតិបុគ្គលសាជីវកម្ម**
Eng. **i**ncorporated association(s)
Fr. **s**ociété enregistrée

ក្រុមដែលមានសមាជិកស្វែងរកចំណេញ ហើយត្រូវបានផ្ដល់នូវសិទ្ធិ និងកាតព្វកិច្ច ។

៧៥. **នីតិបុគ្គលសាធារណៈ**

Eng. **j**uridical person under public law
Fr. **p**ersonne publique / **p**ersonne morale de droit public

ស្ថាប័ន ដែលត្រូវបានបង្កើតឡើង និងគ្រប់គ្រង ដោយច្បាប់សាធារណៈ ដែលមានសិទ្ធិអំណាច ក្នុងការអនុវត្តកិច្ចការរដ្ឋបាល ។

៧៦. **នីតិឯកជន**

Eng. **p**rivate law
Fr. **d**roit privé

វិធានទាំងឡាយ ដែលគ្រប់គ្រងទំនាក់ទំនងគតិយុត្ត រវាងបុគ្គលឯកជន និង បុគ្គលឯកជន ហើយមិនឋិតក្រោមនីតិសាធារណៈទេ ។

# ប

៧៧. **បច្ឆាញាតិផ្ទាល់**
Eng. **d**escendant
Fr. **d**escendant

ជន ឬពួកជន ដែលកើតពីជនមួយពួកទៀត ។
ឧ. កូន ជាបច្ឆាញាតិរបស់ឪពុកម្តាយ ។ ចៅ ជាបច្ឆាញាតិរបស់ជីដូនជីតា ។

៧៨. **បញ្ជីគណនី**
Eng. **a**ccount record
Fr. **r**egistre comptable

តាមក្រមរដ្ឋប្បវេណី មានន័យថា តារាង ឬ របាយការណ៍ ដែលកត់ត្រានូវចលនាចំណូល ចំណាយ ប្រាក់ចំណេញ ឬខាត នៅក្នុងអំឡុងពេលកំណត់ណាមួយ ។

៧៩. **បញ្ជីសារពើភ័ណ្ឌ**
Eng. **i**nventory / **l**ist of properties
Fr. **i**nventaire

បញ្ជីទ្រព្យទាំងអស់ ។

៨០. **បញ្ញើ**
Eng. **b**ailment
Fr. **d**épôt

១-តាមន័យទូទៅ : វត្ថុ ។
២-តាមក្រមរដ្ឋប្បវេណី មានន័យថា កិច្ចសន្យាបញ្ញើ ។

៨១. **បញ្ញើបន្ត**
Eng. **s**ub-bailment
Fr. **s**ous-dépôt

កិច្ចសន្យា ដែលភាគីម្ខាងជាអ្នកទទួលបញ្ញើបន្ត សន្យាទទួលយកវត្ថុបញ្ញើពីភាគីម្ខាងទៀត ដែលជាអ្នកផ្ញើ និងជាអ្នកទទួលបញ្ញើក្នុងកិច្ចសន្យាបញ្ញើមួយផ្សេងទៀត មករក្សាទុក ។

៨២. **បដិគ្គាហក ឬបដិគ្គាហកៈ**
Eng. **d**onee
Fr. **d**onataire

អ្នកទទួលយកទាន (អំណោយ) ។ តាមក្រមរដ្ឋប្បវេណី មានន័យថា ភាគីម្ខាងនៃកិច្ចសន្យាប្រទានកម្ម ដែលយល់ព្រមទទួលយកនូវទ្រព្យសម្បត្តិពីទាយក ដោយមិនផ្តល់តម្លៃតបស្នង ។

៨៣. **បដិទាន**
Eng. **r**estitution
Fr. **r**estitution

ការស្តារឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ ។
ឧ. ការបង្វិលសងវត្ថុ ដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុ ដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រង ទៅកូនបំណុលវិញ ឬការបង្វិលសងវិញ នូវទ្រព្យមរតកដែលអ្នកគ្មានសិទ្ធិខាងសន្តតិកម្ម បានទទួលជាដើម ។

៨៤. **ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់**
Eng. **c**ertificate of possession
Fr. **c**ertificat de possession

លិខិត ដែលមានរូបមន្តយថាភូត ចេញដោយអាជ្ញាធរមានសមត្ថកិច្ច សម្រាប់បញ្ជាក់អំពីសិទ្ធិកាន់កាប់របស់បុគ្គល ឬក្រុមណាមួយ ។

៨៥. **បទដ្ឋានគតិយុត្ត**
Eng. **l**egal norme
Fr. **n**orme juridique / règle de droit

-វិធានច្បាប់ដូចជា ច្បាប់ និងបទបញ្ជាផ្សេងៗ ដែលបានបង្កើតឡើងដោយរដ្ឋ
-វិធានច្បាប់ដែលនាំឱ្យមានតម្លៃបង្ខិតបង្ខំ (តម្រូវឱ្យអនុវត្តតាម) ទោះបីចេញពីប្រភពណាក៏ដោយ (ច្បាប់ សន្ធិសញ្ញា...) ។

៨៦. **បរិបាល**

Eng. **c**aptain / **c**ommander
Fr. **c**apitaine / **c**ommandant

អ្នកដឹកនាំ ត្រួតត្រា បញ្ជា ។

ឧ. បរិបាលនាវា ឬយន្តហោះជាដើម ។

៨៧. **បរិហារកេរ្តិ៍**

Eng. **d**efamation
Fr. **d**iffamation

ការលើកឡើងនូវទទ្បីករណ៍ ឬការទម្លាក់កំហុស ដោយអសុទ្ធចិត្ត ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬដល់កិត្តិស័ព្ទនៃបុគ្គលឬស្ថាប័នដោយសំដី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ ឬតាមលិខិត ឬ គំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយ នៅក្នុងសាធារណជន ឬដាក់តាំងឱ្យសាធារណជនមើល ឬតាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍ ដែលសម្រាប់សាធារណជន ។

៨៨. **បិតុភាព**

Eng. **f**atherhood / **p**aternity
Fr. **p**aternité

ក្រសែញាតិ ដែលទាក់ទងពីឪពុកទៅកូន ។

៨៩. **បុគ្គលភាព**

Eng. **l**egal personality
Fr. **p**ersonnalité juridique

ភាពពេញលក្ខណៈ ជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច ។

៩០. **បុគ្គលឯកជន**

Eng. **p**rivate person
Fr. **p**ersonne privée

បុគ្គល ដែលមានសិទ្ធិ និងកាតព្វកិច្ចនៅក្នុងទំនាក់ទំនងគតិយុត្ត និងដែលត្រូវគ្រប់គ្រងដោយនីតិឯកជន ។

៩១. **បុត្តភាព**

Eng. **a**ffiliation
Fr. **f**iliation

ក្រសែញាតិ ដែលទាក់ទងពីឪពុកម្តាយ ទៅកូនបង្កើតរបស់ខ្លួន ។

៩២. **បុព្វជន**

Eng. **a**scendant
Fr. **a**scendant

ជន ដែលកើតមុនហើយបង្កើតជនមួយពួកទៀត ។

ឧ. ជីដូន ជីតា ឪពុក ម្តាយ ជាបុព្វជនរបស់កូន ចៅ... ។

៩៣. **បុព្វញាតិ**

Eng. **a**ncestor
Fr. **a**ncêtres

១-តាមន័យទូទៅ : មានន័យដូចបុព្វជន ។

២-តាមក្រមរដ្ឋប្បវេណី មានន័យថា ជន ដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន ។

ឧ. ជីដូន ជីតា ឪពុក ម្តាយ មា មីង ជាបុព្វញាតិ របស់ចៅ កូន ក្មួយ... ។

៩៤. **បេតិកភណ្ឌវប្បធម៌**

Eng. **c**ultural heritage
Fr. **p**atrimoine culturel

រាល់ស្នាដៃរបស់មនុស្ស និងរាល់ផលិតផលរបស់ធម្មជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ដែលឆ្លុះបញ្ចាំងនូវដំណាក់កាលនៃការវិវត្តរបស់អរិយធម៌ ឬរបស់ធម្មជាតិ ។

៩៥. **ប្រតិទិនសុរិយគតិ**

Eng. **c**alendar year / **s**olar calendar
Fr. **a**nnée civile

បញ្ជី ឬតារាងចុះចំនួន និងឈ្មោះ ថ្ងៃ ខែ សម្រាប់ប្រើក្នុងមួយឆ្នាំ ដោយគិតតាមដំណើរនៃព្រះអាទិត្យ ។

៩៦. **ប្រតិសិទ្ធិ**

Eng. **s**uccessor
Fr. **a**yant cause

បុគ្គល ដែលទទួលបន្តនូវសិទ្ធិ កាតព្វកិច្ចពីបុគ្គលដទៃ។

៩៧. **ប្រតិសិទ្ធិដោយឡែក**

Eng. **p**articular successor
Fr. **a**yant cause à titre particulier

បុគ្គល ដែលទទួលបន្តសិទ្ធិមួយ ឬច្រើនជាកំណត់ ផ្អែកតាមមូលហេតុនីមួយៗ។

៩៨. **ប្រតិសិទ្ធិសាកល**

Eng. **u**niversal successor
Fr. **a**yant cause à titre universel / **a**yant cause universel

បុគ្គល ដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទូទៅ ពីបុគ្គលដទៃ។

៩៩. **ប្រទានកម្ម**

Eng. **d**onation
Fr. **d**onation

កិច្ចសន្យា ដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យទៅភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។

១០០. **ប្រធានសក្តិ**

Eng. **f**orce majeure
Fr. **f**orce majeure

ព្រឹត្តិការណ៍ ដែលកើតឡើងក្រៅពីឆន្ទៈមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

១០១. **ប្រាតិភោគ**

Eng. **s**ecurity
Fr. **s**ûreté

១-ការធានា ដល់ម្ចាស់បំណុលក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ។

២-មធ្យោបាយមួយដើម្បីធានាការសងកាតព្វកិច្ច។

១០២. **ប្រាក់កក់**

Eng. **e**arnest / **d**eposite
Fr. **a**rrhes / **c**aution

១-ប្រាក់ ដែលបង់ដោយអ្នកទិញទៅឱ្យអ្នកលក់ នៅពេលបង្កើតកិច្ចសន្យា ដើម្បីធានាសិទ្ធិរបស់ខ្លួនក្នុងការរំលាយកិច្ចសន្យា។

២-ប្រាក់បង់សម្រាប់ធានាការជួលវត្ថុអ្វីមួយ ហើយត្រូវសងវិញ នៅពេលប្រគល់វត្ថុនោះ ត្រឡប់ឱ្យវិញ ដោយគ្មានការខូចខាត។

# ផ ព ភ

១០៣. **ផលធម្មជាតិ** 	១-វត្ថុ ដែលកើតឡើង ហើយត្រូវបានធ្វើលទ្ធកម្ម តាមវិធីប្រើធម្មតា ។
Eng. **n**atural fruits / **n**atural produce	២-ផលិតផល ដែលកើតអំពីដីធ្លី ឬកូនសត្វស្រុក ដែលកើតពីមេបាវាមក ។
Fr. **f**ruits naturels

១០៤. **ផលប្រយោជន៍ពិសេស** 	ទ្រព្យ ដែលបុគ្គល (សន្តតិជន) បានទទួលជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលជាអច្ច័យទានពីមតកជន ។
Eng. **s**pecial benefit
Fr. **a**vantages spéciaux

១០៥. **ផលស៊ីវិល** 	ប្រាក់ ឬវត្ថុផ្សេងៗ ដែលទទួលជាថ្នូរចំពោះការប្រើវត្ថុណាមួយ ។
ឧ. ការប្រាក់ ឬឈ្នួលផ្ទះជាដើម ។
Eng. **l**awful fruit / **i**ncome of capital
Fr. **f**ruits civils

១០៦. **ផលុបភោគ** 	សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុ ដែលជាកម្មសិទ្ធិអ្នកដទៃក្នុងអំឡុងពេលមានកំណត់ណាមួយ ដែលមិនឱ្យលើសពីមួយជីវិតរបស់ផលុបភោគី ។
Eng. **u**sufruct
Fr. **u**sufruit

១០៧. **ផលុបភោគី** 	បុគ្គល ដែលទទួលបានផលុបភោគ ។
Eng. **u**sufructuary
Fr. **u**sufruitier

១០៨. **ពិន័យស៊ីវិល** 	ទណ្ឌកម្មមួយប្រភេទ ដែលកំណត់ឱ្យអ្នកប្រព្រឹត្តខុសនឹងបញ្ញត្តិនៃច្បាប់រដ្ឋប្បវេណី បង់ប្រាក់ពិន័យ តាមចំនួនណាមួយជាកំណត់ ។
Eng. **c**ivil fine
Fr. **a**mende civile

១០៩. **ព្យាករ** 	ធ្វើឱ្យប្រាកដ ឱ្យជាក់ច្បាស់ ទាយ ។
Eng. **f**oresee
Fr. **p**révoir

១១០. **ព្យាកុលភាព** 	១-ករណី ដែលកម្មសិទ្ធិ ឬសិទ្ធិប្រត្យក្សផ្សេងទៀត ដែលមានលើវត្ថុតែមួយធ្លាក់ទៅលើបុគ្គលតែម្នាក់ ឬករណី ដែលសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀត ដែលមានកម្មវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់ ។
២-មធ្យោបាយរំលត់កាតព្វកិច្ច ដែលជនម្នាក់ប្រមូលឱ្យមូលមកលើដៃខ្លួនតែម្នាក់នូវគុណភាពជាម្ចាស់បំណុលផង និងកូនបំណុលផង ។
Eng. **m**erger of rights
Fr. **c**onfusion

១១១. **ភតិកៈ** 	ភាគីម្ខាងនៃភតិសន្យា ដែលសន្យាថានឹងបង់ថ្លៃឈ្នួលដើម្បីជាថ្នូរនឹងការទទួលបាននូវសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុណាមួយរបស់ភតិបតី ។
Eng. **l**essee
Fr. **p**reneur / **l**ocataire

១១២. **ភតិបតី**

Eng. **l**essor
Fr. **b**ailleur

ភាគីម្ខាងនៃភតិសន្យា ដែលសន្យាថា ឱ្យភតិកៈ ប្រើប្រាស់ និងអាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃឈ្នួល។

១១៣. **ភតិសន្យា**

Eng. **l**ease
Fr. **b**ail

កិច្ចសន្យាមួយ ដែលភាគីម្ខាងឱ្យភាគីម្ខាងទៀត ប្រើប្រាស់ និងអាស្រ័យផល ពីវត្ថុណាមួយដោយយកថ្លៃឈ្នួល។

១១៤. **ភាគបម្រុង**

Eng. **l**egally secured portions
Fr. **r**éserve héréditaire / **r**éserve légale

ភាគនៃទ្រព្យសម្បត្តិរបស់មតកជន ដែលបច្ឆាញាតិផ្ទាល់ ឬឪពុក ម្ដាយ ឬជីដូន ជីតា និង សហព័ទ្ធរបស់មតកជននោះ អាចទាមទារបាន តាមការកំណត់របស់ច្បាប់។

១១៥. **ភារធារី**

Eng. **c**hargé d'affaires
Fr. **c**hargé d'affaires

១-ប្រមុខបេសកកម្មការទូតថ្នាក់ទី៣ នៅជាអចិន្ត្រៃយ៍អមក្រសួងការបរទេស។

២-សមាជិកបេសកកម្មការទូតទទួលបន្ទុកទទួលខុសត្រូវជាប្រមុខបេសក-កម្ម ការទូតស្ដីទី ក្នុងករណីអវត្តមានរបស់ប្រមុខបេសកកម្មការទូត។

៣-តាមក្រមរដ្ឋប្បវេណី មានន័យថា មន្ត្រីការទូត ដែលទទួលភារកិច្ចជាមន្ត្រីអគ្រានុកូលដ្ឋាន ប្រចាំស្ថានទូត។

# ម

១១៦. **មតិក**
Eng. **e**state / **h**eritage
Fr. **h**éritage

ទ្រព្យសម្បត្តិជាកេរទាំងឡាយ ដែលបុគ្គលម្នាក់ (មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់ ។

១១៧. **មតកជន**
Eng. **d**eceased
Fr. **d**éfunt

ជន ដែលបានស្លាប់ទៅហើយ ។

១១៨. **មតកសាសន៍**
Eng. **t**estament / **w**ill
Fr. **t**estament

លិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព ។

១១៩. **មហន្តរាយ**
Eng. **d**estruction
Fr. **d**estruction

សេចក្តីវិនាសបាត់បង់ ។

១២០. **មហាសន្និបាតសមាជិក**
Eng. **g**eneral meeting of members / **g**eneral assembly
Fr. **a**ssemblée générale

១-ការប្រជុំពេញអង្គ របស់នីតិបុគ្គលសាជីវកម្ម ដែលធ្វើឡើងរវាងសមាជិកដើម្បីអនុម័តកិច្ចការសំខាន់ៗរបស់នីតិបុគ្គលនោះ ។
២-អង្គការសម្រេចថ្នាក់ខ្ពស់បំផុត នៃនីតិបុគ្គលសាជីវកម្ម ដែលចូលរួមដោយសមាជិក ដើម្បីសម្រេចកិច្ចការសំខាន់ៗរបស់នីតិបុគ្គលនោះ ។

១២១. **មាត្រដ្ឋាន**
Eng. **c**riteria / **s**tandard
Fr. **s**tandard / **é**chelle

រង្វាស់ រង្វាល់ ខ្នាត កម្រិត បែប ប្រភេទ ដែលជាមូលដ្ឋាននៃការវិនិច្ឆ័យ ។

១២២. **មូលបត្រ**
Eng. **s**ecurity
Fr. **o**bligation

ប័ណ្ណ ដែលតំណាងឱ្យសិទ្ធិលើកម្មសិទ្ធិរបស់ម្ចាស់ប័ណ្ណនោះទៅលើក្រុមហ៊ុន (ឧ.ប័ណ្ណហ៊ុន) តំណាងឱ្យទំនាក់ទំនងផ្នែកឥណទេយ្យ រវាងម្ចាស់ប័ណ្ណនោះ និងក្រុមហ៊ុន ឬរដ្ឋាភិបាល (ឧ.ប័ណ្ណរតនាគារ) ឬតំណាងឱ្យសិទ្ធិផ្សេងទៀតរបស់ម្ចាស់ប័ណ្ណនោះ ។

១២៣. **មូលបត្រឥណទេយ្យ**
**(ឧបករណ៍អាចជួញដូរបាន)**
Eng. **n**egotiable instrument
Fr. **v**aleurs mobilières

១-តាមក្រមរដ្ឋប្បវេណី មានន័យថា មូលបត្រ ដែលតំណាងឱ្យផលប្រយោជន៍ (សិទ្ធិ) ជាទ្រព្យសម្បត្តិ និងដែលតម្រូវការផ្ទេរ ឬការអនុវត្តនូវសិទ្ធិត្រូវតែធ្វើតាមមូលបត្រ ។
២-តាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ : ប័ណ្ណ ដែលផ្សាយចេញពីរដ្ឋ គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ឬក្រុមហ៊ុនវិនិយោគ ដើម្បីខ្ចីបុលប្រាក់ពីសាធារណជនតាមរយៈពេលកំណត់ និងអត្រាការប្រាក់ច្បាស់លាស់ គឺជាប័ណ្ណតំណាងឥណទេយ្យ (តំណាងបំណុលត្រូវទារ) ដែលអ្នកកាន់អាចយកទៅជួញដូរបាននៅលើទីផ្សារមួយ គ្រប់គ្រងដោយច្បាប់ ។ មូលបត្រ

ឥណទេយ្យមានដូចជា ប័ណ្ណរតនាគារ សញ្ញាប័ណ្ណ ប័ណ្ណបេឡា ។ល។

១២៤. **មូលហេតុគតិយុត្ត**

Eng. **l**egal basis
Fr. **m**otifs légaux / **c**ause juridique

មូលដ្ឋាន ដែលធ្វើឱ្យសកម្មភាពជាក់លាក់ណាមួយ មានភាពត្រឹមត្រូវតាមច្បាប់ ។

ឧ. សិទ្ធិជួល គឺជាមូលហេតុគតិយុត្តនៃការកាន់កាប់របស់ភតិកៈ ។

១២៥. **មោឃភាព**

Eng. **n**ullity
Fr. **n**ullité

១-ភាពពុំមានអានុភាពតាមផ្លូវច្បាប់ នៃសកម្មភាពគតិយុត្ត ដែលផ្ទុយនឹងបញ្ញត្តិអំពីនីតិវិធីនៃបណ្ដឹង ។

២-ទណ្ឌកម្ម ដែលប្រកាសដោយចៅក្រមលុបបំបាត់ចោលជាប្រតិសកម្មនូវលិខិតគតិយុត្ត មិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬសកម្មភាពណាមួយដែលផ្ទុយពីនីតិវិធីនៃច្បាប់ ។

# រ ល

១២៦. **រតនសម្បត្តិ**
Eng. **a**ncestral heirloom
Fr. **s**ouvenir de famille

១-តាមន័យទូទៅ : វត្ថុ ដែលមានតម្លៃ ។
២-តាមក្រមរដ្ឋប្បវេណី មានន័យថា ចលនវត្ថុប្រចាំត្រកូល ដែលជាកេរដំណែលពីបុព្វជន ។

១២៧. **រូបវន្តបុគ្គល**
Eng. **n**atural person
Fr. **p**ersonne physique

មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល ។

១២៨. **រូបិយវត្ថុ**
Eng. **m**oney
Fr. **m**onnaie

ឧបករណ៍កំណត់ដោយច្បាប់ ដែលប្រើប្រាស់ជាមធ្យោបាយសម្រាប់ដោះដូរ ។
ឧ. ប្រាក់រៀល ជារូបិយវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា ។

១២៩. **លក្ខន្តិកៈ**
Eng. **m**emorandum and articles of association / **by**(e)-laws
Fr. **s**tatut

លិខិតបង្កើតនីតិបុគ្គល ដែលមានចុះនិទ្ទេសចាំបាច់ ខ្វះមិនបាន អំពីចំណុចសំខាន់ៗដូចជា គោលបំណង នាមករណ៍ ទីតាំងនៃទីស្នាក់ការកណ្តាល ។ល ។

១៣០. **លទ្ធកម្ម**
Eng. **a**cquisition
Fr. **a**cquisition

១-ការទទួលបាន ។
២-ការបានឡើងជាម្ចាស់សិទ្ធិនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួនក្តី ដោយទិញ ឬដោយដូរក្តី ។

១៣១. **លិខិតយថាភូត**
Eng. **a**uthentic deed
Fr. **a**cte authentique

លិខិត ធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ ។ តាមន័យចង្អៀតគឺជា លិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី ។

១៣២. **លិខិតឯកជន**
Eng. **p**rivate deed
Fr. **a**cte sous-seing privé

លិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ ។

# វ

១៣៣. **វត្ថុចម្បង**
Eng. **p**rincipal thing
Fr. **c**hose principale

វត្ថុ ដែលជាតួប្រធាននៃវត្ថុចំណុះ ។

១៣៤. **វត្ថុចំណុះ**
Eng. **a**ccessory thing
Fr. **c**hose accessoire

វត្ថុ ដែលមិនមែនជាសមាសភាគនៃវត្ថុចម្បង ហើយដែលកម្មសិទ្ធិករនៃវត្ថុចម្បង បានភ្ជាប់ទៅនឹងវត្ថុចម្បង ក្នុងគោលបំណងសេដ្ឋកិច្ចនៃវត្ថុចម្បងជាបន្តបន្ទាប់ ។

១៣៥. **វិការៈ**
Eng. **d**efect
Fr. **v**ice / **d**éfaut

ការប្រែប្រួលចាកពីភាពប្រក្រតី ។

១៣៦. **វិជ្ជាជីវៈ**
Eng. **o**ccupation
Fr. **p**rofession

មុខតំណែង មុខការ របរសម្រាប់ចិញ្ចឹមជីវិត ។

១៣៧. **វិសាលភាព**
Eng. **s**cope
Fr. **é**tendue

ទំហំ ភាពទូលំទូលាយ ភាពលាតសន្ធឹង ។

១៣៨. **វិសុណ្ឋាបនិក**
Eng. **s**equestrator / **s**equestration
Fr. **s**équestre

១-ជនថែរក្សាវត្ថុ ដែលកំពុងមានវិវាទ ។
២-ការប្រគល់វត្ថុ ដែលកំពុងមានវិវាទទៅឱ្យតតិយជនណាម្នាក់ថែរក្សា ។

# ស

១៣៩. **សកម្មភាព**
Eng. **a**ct
Fr. **a**cte

តាមក្រមរដ្ឋប្បវេណីមានន័យថា ការបង្ហាញឆន្ទៈ តាមរយៈកិច្ចសន្យា ឬជាឯកតោភាគី។

១៤០. **សកម្មភាពសុពល**
Eng. **v**alid act
Fr. **a**cte valuable

សកម្មភាព ដែលធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវ ដោយច្បាប់ និងមានអានុភាពតាមផ្លូវច្បាប់។

១៤១. **សកម្មភាពឯកតោភាគី**
Eng. **u**nilateral act
Fr. **a**cte unilatéral

សកម្មភាព ដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដោយការបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យ ដោយភាគីតែម្ខាង ឬដោយអនុវត្តសិទ្ធិ ដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់។

១៤២. **សច្ចានុមតិ**
Eng. **r**atification
Fr. **r**atification

១-ការយល់ព្រមទទួលស្គាល់ ដែលមានអានុភាពប្រតិសកម្ម។
ឧ.ក្មេងម្នាក់ (១៧ឆ្នាំ) ធ្វើកិច្ចសន្យាមួយ កិច្ចសន្យានោះមិនពេញលក្ខណៈច្បាប់ទេ។ តែបើក្មេងនោះ ផ្តល់សច្ចានុមតិ (ផ្តល់ការយល់ព្រម) លើកិច្ចសន្យានោះ ក្រោយពេលវាធំពេញវ័យ (១៨ឆ្នាំ) កិច្ចសន្យានោះ ក្លាយជាកិច្ចសន្យាពេញលក្ខណៈច្បាប់។
២-ការទទួលស្គាល់របស់ភាគី ចំពោះសកម្មភាពបណ្តឹង ដែលបានធ្វើឡើងដោយបុគ្គលដែលខ្វះសិទ្ធិតំណាងដោយអាណត្តិ ហើយការទទួលស្គាល់នោះត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង។

១៤៣. **សន្តតិកម្ម**
Eng. **s**uccession
Fr. **s**uccession

ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។

១៤៤. **សន្តតិជន**
Eng. **s**uccessor
Fr. **h**éritier

ជន ដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

១៤៥. **សមត្ថជន**
Eng. **p**erson of full capacity
Fr. **c**apable /
**p**ersonne capable

ជនទាំងឡាយ ក្រៅពីជនទៅក្រោមអាណាព្យាបាលទូទៅ និងក្រៅពីជនទៅក្រោមហិតូបត្ថម្ភ និងអនីតិជន លើកលែងអនីតិជន ដែលទទួលបានអត្តាធីនភាព។

១៤៦. **សមត្ថភាព**
Eng. **c**apacity
Fr. **c**apacité

លក្ខណសម្បត្តិរបស់បុគ្គល ដែលតម្រូវដោយច្បាប់រួមមាន ៖
-លក្ខណសម្បត្តិ ដែលអាចក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច (សមត្ថភាពទទួលសិទ្ធិ)។
-លក្ខណសម្បត្តិ ដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាម

ផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន (សមត្ថភាពខាងឆន្ទៈ)។
-លក្ខណសម្បត្តិ ដែលអាចធ្វើឱ្យសកម្មភាពរបស់ខ្លួន មានអានុភាពតាមផ្លូវច្បាប់ (សមត្ថភាពក្នុងការធ្វើសកម្មភាព)។

១៤៧. **សន្ធិសញ្ញា**
Eng. **t**reaty
Fr. **t**raité

កិច្ចព្រមព្រៀងអន្តរជាតិ ដែលធ្វើឡើងជាលាយលក្ខណ៍អក្សររវាងរដ្ឋនិងរដ្ឋ រវាងរដ្ឋនិងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ ហើយស្ថិតនៅក្រោមការគ្រប់គ្រង នៃនីតិអន្តរជាតិសាធារណៈ ទោះបីជាកិច្ចព្រមព្រៀងនោះមានឈ្មោះជាអ្វីក៏ដោយ (ធម្មនុញ្ញ សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា...) ដើម្បីបង្កើតអានុភាពគតិយុត្ត។

១៤៨. **សមាសភាគនៃវត្ថុ**
Eng. **c**omponents of a thing
Fr. **b**iens composants / **c**omposant d'une chose

ភាគនៃវត្ថុ ដែលរួមបញ្ចូលជាវត្ថុតែមួយ ហើយដែលមិនអាចបែងចែកបាន ដោយមិនបំបែកវត្ថុនោះ ឬដោយមិនផ្លាស់លក្ខណៈដើមនៃវត្ថុនោះ។
ឧ. អគារសំណង់ដែលសង់លើដីហើយមិនអាចប្តូរកន្លែងបាន ឬពូជដែលសាបលើដីជាសមាសភាគនៃដី។

១៤៩. **សហគមន៍**
Eng. **c**ommunity
Fr. **c**ommunauté

១-ដំណើរជាមួយគ្នា ប្រជុំភូមិ ឬតំបន់ ដែលអ្នកស្រុកប្រកបរបរចូលគ្នា។
២-ក្រុមមនុស្ស ដែលចងភ្ជាប់ដោយតំបន់ ទំនាក់ទំនងញាតិលោហិត ទំនៀមទម្លាប់ប្រពៃណី សាសនាជាដើម។
ឧ.សហគមន៍ចិញ្ចឹមត្រី សហគមន៍ជនជាតិភាគតិច នៅតំបន់ព្រៃភ្នំដាច់ស្រយាល។

១៥០. **សហព័ទ្ធ**
Eng. **s**pouse
Fr. **c**onjoint(e)

ប្តី ឬប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះ ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

១៥១. **សហសន្តតិជន**
Eng. **c**o-successor
Fr. **c**o-héritier

អ្នកដែលត្រូវចូលរួមក្នុងការចែកមរតកណាមួយ (ម.ព. សន្តតិជន)។

១៥២. **សាខាញាតិ**
Eng. **c**ollateral relative
Fr. **c**ollatéraux

ញាតិ ដែលបែកចេញជាមែកចាងពីអ្នកបង្កើតរួម ដូចជា បងប្អូនបង្កើត មីង មា ក្មួយ បងប្អូនជីដូនមួយ។

១៥៣. **សាធនភាព**
Eng. **s**olvency
Fr. **s**olvabilité

ភាពដែលអាចសងបំណុលទាំងអស់ តាមការកំណត់ត្រូវសង។

១៥៤. **សារការី**
Eng. **n**otary public
Fr. **n**otaire

មន្ត្រីសាធារណៈ ដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឱ្យមានការបញ្ជាក់។

១៥៥. **សារវន្ត**
Eng. **f**undamental
Fr. **f**ondamental

ដែលមានសារប្រយោជន៍ ដែលសំខាន់ជាមូលដ្ឋាន ប្រកបដោយខ្លឹមសារ ។

១៥៦. **សិទ្ធិឃាត់ទុក**
Eng. **r**ight of retention
Fr. **d**roit de rétention

សិទ្ធិប្រាតិភោគប្រត្យក្សមួយប្រភេទ របស់អ្នកកាន់កាប់វត្ថុអ្នកដទៃ ដែលមានសិទ្ធិលើបំណុល ក្នុងការឃាត់ទុកវត្ថុនោះ រហូតដល់ពេលដែលខ្លួនបានទទួលការសងចំពោះសិទ្ធិលើបំណុល ។

១៥៧. **សិទ្ធិជួលអចិន្ត្រៃយ៍**
Eng. **p**erpetual lease right / **l**ong lease right
Fr. **d**roit sur le bail emphytéotique / **e**mphytéose

សិទ្ធិជួលអចលនវត្ថុ ដែលមានរយៈពេលចាប់ពី ១៥ឆ្នាំឡើងទៅ ។

១៥៨. **សិទ្ធិប្រត្យក្ស ឬសិទ្ធិ ភណ្ឌិក**
Eng. **r**eal right
Fr. **d**roit réel

សិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន ។

១៥៩. **សិទ្ធិប្រាតិភោគប្រត្យក្ស**
Eng. **r**eal security right
Fr. **s**ûreté réelle

សិទ្ធិប្រត្យក្សមួយប្រភេទ រួមមាន សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទានដែលត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ច ។

១៦០. **សិទ្ធិប្រើប្រាស់**
Eng. **r**ight of use
Fr. **d**roits d'usage

សិទ្ធិអាស្រ័យផលលើអចលនវត្ថុ ត្រឹមកម្រិតនៃសេចក្តីត្រូវការរបស់ម្ចាស់សិទ្ធិ និងគ្រួសាររបស់ខ្លួន ។

១៦១. **សិទ្ធិលើការបញ្ចាំ**
Eng. **p**ledge
Fr. **d**roit de gage / **n**antissement

សិទ្ធិកាន់កាប់វត្ថុ ដែលបានពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលសំណងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ។

១៦២. **សិទ្ធិអាស្រ័យនៅ**
Eng. **r**ight of residence
Fr. **d**roit d'habitation

សិទ្ធិកាន់កាប់ មួយចំណែកនៃអគារត្រឹមកម្រិតនៃសេចក្តីត្រូវការសម្រាប់ការរស់នៅរបស់ម្ចាស់សិទ្ធិអាស្រ័យនៅ និងគ្រួសាររបស់ខ្លួន ។

១៦៣. **សិល្បការ្យ**
Eng. **w**orkmanship
Fr. **o**uvrage d'art

ផលទាំងពួងដែលកើតមកពីស្នាដៃមនុស្ស ។

១៦៤. **សុពលភាព**
Eng. **v**alidity
Fr. **v**alidité

ភាវៈមានអានុភាពអនុវត្តតាមផ្លូវច្បាប់ ។

១៦៥. **សេវភាព**
Eng. **e**asement
Fr. **s**ervitude

១-សិទ្ធិប្រត្យក្សមួយប្រភេទ សំដៅទៅលើសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃសម្រាប់ជាប្រយោជន៍ ដល់ដីរបស់ខ្លួន ដោយយោងតាមគោលបំណងដូចបានកំណត់នៅក្នុងកិច្ចសន្យាបង្កើត ។

២-បន្ទុកដែលផ្ទុកលើអចលនវត្ថុមួយ (ដីបម្រើ ឬដីក្រោម) ដើម្បីជាប្រយោជន៍ដល់អចលនវត្ថុមួយទៀត (ដីប្រើ ឬដីលើ) ដែលជាកម្មសិទ្ធិករ

ផ្សេងទៀត។ ឧ. ស្រែក្រោមមានសេរីភាព ខាងទទួលទឹកពីស្រែលើ។ ស្រែក្រោមហៅថា ស្រែបម្រើ ហើយស្រែលើហៅថា ស្រែប្រើ។

១៦៦. **ស្ថាប័នរដ្ឋបាល**
Eng. **a**dministrative governmental institution
Fr. **i**nstitution administrative

១-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកិច្ចការរដ្ឋបាលសាធារណៈ។
២-តាមក្រមរដ្ឋប្បវេណីនេះ មានន័យថា ស្ថាប័នសាធារណៈ ដែលច្បាប់ការងារប្រគល់អំណាចឱ្យ។

១៦៧. **សុំកូនធម្មតា**
Eng. **s**imple adoption
Fr. **a**doption simple

ការសុំកូន ដែលកូននោះអាចជាអនីតិជន ឬ នីតិជន ដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

១៦៨. **សុំកូនពេញលេញ**
Eng. **f**ull adoption
Fr. **a**doption plénière

ការសុំអនីតិជន ដែលមានអាយុក្រោម៨ឆ្នាំយកធ្វើជាកូនសុំ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

១៦៩. **ស្វីការ**
Eng. **a**cceptance
Fr. **a**cceptation

ការសំដែងឆន្ទៈ ដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

# ហ

១៧០. **ហានិភ័យ**

Eng. **r**isk
Fr. **r**isque

ការប្រថុយនឹងការខូចខាត ឬការបាត់បង់។

១៧១. **ហិតូបត្ថម្ភ**

Eng. **p**artial guardianship / **c**uratorship
Fr. **c**uratelle

ការគ្រប់គ្រងលើជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។

១៧២. **ហិតូបត្ថម្ភកៈ**

Eng. **c**urator
Fr. **c**urateur

ជនដែលតុលាការចាត់តាំងឱ្យអនុវត្តហិតូបត្ថម្ភ (ម.ព. ហិតូបត្ថម្ភ)។

១៧៣. **ហ៊ីប៉ូតែក**

Eng. **h**ypothec
Fr. **h**ypothèque

សិទ្ធិប្រាតិភោគប្រត្យក្សមួយប្រភេទ។ ហ៊ីប៉ូតែក ផ្តល់ឱ្យម្ចាស់បំណុលនូវសិទ្ធិទទួលការសង ចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬតតិយជនដោយមិនផ្ទេរការកាន់កាប់។

១៧៤. **ហ៊ីប៉ូតែកធានាបំណុលអណ្តែត**

Eng. **h**ypothec for floating debt
Fr. **h**ypothèque garantissant la dette flottante

ហ៊ីប៉ូតែកមួយប្រភេទ ដែលអាចបង្កើតដើម្បីធានាកាតព្វកិច្ចមិនកំណត់ដែលកើតមានឡើង រវាងម្ចាស់បំណុល និងកូនបំណុល ដោយសារការជួញដូរជានិរន្តរ៍ ដែលមានប្រភេទជាកំណត់ក្នុងកម្រិតនៃចំនួនអតិបរមា។

# អ

១៧៥. **អង្គហេតុ** — រឿងហេតុ ដែលកើតឡើងនាំឱ្យមានបច្ច័យគតិយុត្ត ជាកំណត់។

Eng. **f**act
Fr. **f**ait

១៧៦. **អចលនវត្ថុ** — -ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរ ទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំរុក្ខជាតិ ។ល។

-សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិកលើអចលនវត្ថុ និង ចលនវត្ថុទាំងឡាយ ដែលច្បាប់បានកំណត់ថា ជាអចលនវត្ថុ។

Eng. **i**mmovable / **r**eal estate
Fr. **i**mmeuble

១៧៧. **អច្ច័យទាន** — ប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។

Eng. **t**estamentary gift
Fr. **l**egs

១៧៨. **អច្ច័យទានមានកំណត់** — ប្រទានកម្ម ដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ តាមរយៈមតកសាសន៍។

Eng. **s**pecific testamentary gift
Fr. **l**egs à titre particulier

១៧៩. **អច្ច័យទានសកល** — ប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែក ដែលកំណត់ទៅតាមភាគតាមរយៈ មតកសាសន៍។

Eng. **r**esiduary testamentary gift / **u**niversal testamentary gift
Fr. **l**egs à titre universel / **l**egs universel

១៨០. **អច្ច័យលាភី** — បុគ្គលដែលបានទទួលអច្ច័យទាន។

Eng. **t**estamentary donee
Fr. **l**égataire

១៨១. **អច្ចាសន្ន** — គ្រោះថ្នាក់ ដែលហៀបនឹងកើតឡើងយ៉ាងពិតប្រាកដ។

Eng. **i**mpending danger
Fr. **d**anger imminent

១៨២. **អឡ្លសិទ្ធិ** — ស្ថានភាពនៃជន ដែលមានកម្មសិទ្ធិលើដីជាប់គ្នា មានកម្មសិទ្ធិរួម ដោយមានភាពអវិភាគលើជញ្ជាំង ឬកំពែងដូចជា ស្នាមភ្លោះ ភ្លឺ របងជាអាទិ៍ ដែលនៅត្រង់ព្រំខ័ណ្ឌដី ឬអាគារលើដីនោះ។

Eng. **i**ndivisible joint-ownership
Fr. **m**itoyenneté

១៨៣. **អត្តាធីនភាព** — ស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបានរួចផុត ពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។

Eng. **e**mancipation
Fr. **é**mancipation

១៨៤. **អត្រានុកូលដ្ឋាន**
Eng. **c**ivil status
Fr. **é**tat-civil

ចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងឋានៈនៅក្នុងគ្រួសារ ហើយដែលបង្កើតឱ្យមានសិទ្ធិ និង ករណីយកិច្ច។
ឧ. លិខិតអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព។

១៨៥. **អធិកលាភ**
Eng. **a**dded value
Fr. **l**a plus-value

តម្លៃលើសនៃទ្រព្យណាមួយពីតម្លៃមុន។

១៨៦. **អធិការ**
Eng. **i**nspector
Fr. **i**nspecteur

តាមក្រមរដ្ឋប្បវេណី មានន័យថា បុគ្គលដែលតុលាការជ្រើសតាំង តាមការទាមទាររបស់អភិបាល ដើម្បីធ្វើការស្រាវជ្រាវអំពីទ្រព្យសម្បត្តិ ដែលជាវិភាគទានក្រៅពីប្រាក់ ឬទ្រព្យសម្បត្តិ ដែលបុគ្គលណាម្នាក់ បានសន្យានៅក្នុងលក្ខន្តិកៈនៃការបង្កើតនីតិបុគ្គល ថានឹងធ្វើអនុប្បទានទៅឱ្យនីតិបុគ្គលនោះ ក្រោយពីការបង្កើតនីតិបុគ្គល។

១៨៧. **អនីតិជន**
Eng. **m**inor
Fr. **m**ineur

ជន ដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬ ជនដែលមានអាយុក្រោម ១៨ឆ្នាំ។

១៨៨. **អនុតំណាង**
Eng. **s**econdary representative
Fr. **s**ous-représentant

អ្នកដែលជ្រើសតាំងឡើង ដោយអ្នកតំណាង ហើយដែលមានសិទ្ធិ និងករណីយកិច្ចចំពោះម្ចាស់សិទ្ធិ ដូចអ្នកតំណាងដែរ។

១៨៩. **អនុប្បទាន**
Eng. **t**ransfer / **a**ssignment
Fr. **c**ession

ការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។
ឧ. អនុប្បទានភាគហ៊ុន (ការលក់ភាគហ៊ុន)។

១៩០. **អភ័ព្វបុគ្គល**
Eng. **p**erson disqualified for succession
Fr. **i**ndigne

បុគ្គលដែលពុំអាចក្លាយជាសន្តតិជន ឬពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន។

១៩១. **អភិបាល**
Eng. **m**anager / **m**anagement
Fr. **g**érant / **g**estion

១-អ្នកគ្រប់គ្រង ការគ្រប់គ្រង។
២-តាមក្រមរដ្ឋប្បវេណី មានន័យថា អង្គភាពមួយដើម្បីអនុវត្តកិច្ចការរបស់នីតិបុគ្គល។

១៩២. **អយ្យការ**
Eng. **p**ublic prosecution / prosecution departement
Fr. **p**arquet / ministère public

ស្ថាប័ន ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា និងការពារផលប្រយោជន៍សាធារណៈ។

១៩៣. **អវិភាគីយ៍** ដែលមិនអាចបំបែកបាន ។
Eng. **i**ndivisible
Fr. **i**ndivisible

១៩៤. **អសាធនីយ៍** ដែលគ្មានលទ្ធភាពសងបំណុលទាំងអស់បាន ។
Eng. **i**nsolvent
Fr. **i**nsolvable

១៩៥. **អហេតុកផល (សេចក្ដីចម្រើនដោយឥតហេតុ)** ការទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬពលកម្មរបស់អ្នកដទៃដោយគ្មានមូលហេតុ តាមផ្លូវច្បាប់ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃដោយសារការទទួលផលនោះ ។
Eng. **u**njust enrichment
Fr. **e**nrichissement sans cause

១៩៦. **អាជ្ញាយុកាល** អំឡុងពេលមួយ ដែលកំណត់ដោយច្បាប់ ។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ ។
Eng. **p**rescription
Fr. **p**rescription

១៩៧. **អាណត្តិ** កិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយកប្រគល់សិទ្ធិអំណាចទៅឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហកធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក ។
Eng. **m**andate
Fr. **m**andat

១៩៨. **អាណាព្យាបាល** ការគ្រប់គ្រង បីបាច់ថែរក្សាទ្រព្យសម្បត្តិ រូបកាយ របស់អនីតិជន ដែលគ្មានអ្នកអនុវត្តអំណាចមេបា ឬរបស់អសមត្ថជន ។
Eng. **g**uardianship
Fr. **t**utelle

១៩៩. **អាទិភាព** ភាពខាងដើម ភាពដំបូង ការផ្ដល់ប្រៀបឱ្យមុនគេ ។
Eng. **p**riority
Fr. **p**riorité

២០០. **អានុភាព** ផលគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្ត ដូចជា កិច្ចសន្យា ច្បាប់ សេចក្ដីសម្រេចរបស់តុលាការ សេចក្ដីសម្រេចរបស់រដ្ឋបាល ។ល ។
Eng. **e**ffect
Fr. **e**ffet

២០១. **អានុភាពប្រតិសកម្ម** ១-ឥទ្ធិពលទៅលើសកម្មភាពពីអតីតកាល ដោយសកម្មភាពស្របតាមលក្ខខណ្ឌគតិយុត្ត ។
២-អានុភាពនៃលក្ខខណ្ឌគតិយុត្ត ដែលមានទៅលើសកម្មភាពពីអតីតកាល ។
Eng. **r**etroactive effect
Fr. **e**ffet rétroactif

២០២. **អាហារកាតព្វកិច្ច** កិច្ច ដែលត្រូវតែបំពេញតាមច្បាប់ ឬតាមសេចក្ដីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្ដល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា ។
Eng. **a**limentary obligation
Fr. **o**bligation alimentaire

២០៣. **អំណាចមេបា** សិទ្ធិ និងករណីកិច្ចក្នុងការបីបាច់ថែរក្សាកូន ដែលជាអនីតិជន និងគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូននោះ ។
Eng. **p**arental power
Fr. **a**utorité parentale

២០៤. **អំពើអនីត្យានុកូល**

Eng. **t**ort

Fr. **d**élit civil /
**a**cte dommageable
extra-contractuel

អំពើ ដែលបំពានដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ ដោយកំហុសចេតនា ឬ អចេតនា។

# ឱ ឯ

២០៥. **ឧបកម្មសិទ្ធិអវិភាគ** — ស្ថានភាពដែលបុគ្គលច្រើននាក់មានសិទ្ធិលើទ្រព្យសម្បត្តិដែលក្រៅពីកម្មសិទ្ធិ។ ឧ. ផលុបភោគ សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ សិទ្ធិជួលអចិន្ត្រៃយ៍ជាអាទិ៍ របស់បុគ្គលច្រើននាក់។
Eng. **q**uasi-indivisible property
Fr. **q**uasi-indivision

២០៦. **ឧបភោគីនៃសិទ្ធិលើបំណុល** — អ្នក ដែលមិនមែនជាម្ចាស់បំណុល តែមើលទៅ ហាក់ដូចជាម្ចាស់បំណុល។
Eng. **q**uasi-holder of claim
Fr. **c**réancier apparent

២០៧. **ឧបាគមន៍** — លទ្ធកម្មសិទ្ធិលើវត្ថុដោយសារជាប់គ្នា ការលាយច្របល់គ្នា ឬការកែច្នៃវត្ថុ។
Eng. **a**ccession
Fr. **a**ccession

២០៨. **ឧបាទេសកម្ម** — ឋានៈមួយ ដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់ (ឧបា-ទេសកម្មអាចសំដៅ ទៅលើវត្ថុផងដែរ)។
Eng. **s**ubrogation
Fr. **s**ubrogation

២០៩. **ឧបាទេសិក** — ជន ដែលទទួលស្នងសិទ្ធិតាមផ្លូវច្បាប់ ឬទទួលស្នងការទាមទាររបស់បុគ្គលម្នាក់ទៀតតាមរយៈឧបាទេសកម្ម។
Eng. **s**ubrogee
Fr. **s**ubrogé

២១០. **ឯកច្ឆ័ន្ទ** — ដែលមានការយល់ព្រមទាំងអស់គ្នា។
Eng. **u**nanimous
Fr. **u**nanime

២១១. **ឯកសិទ្ធិ** — សិទ្ធិ ដែលទទួលបាននូវការសងពីទ្រព្យដែលជាកម្មវត្ថុនៃឯកសិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។
Eng. **p**rivilege
Fr. **p**rivilège

# សន្ធានុក្រម

# នីតិវិធីរដ្ឋប្បវេណី

# សទ្ទានុក្រមនីតិវិធីរដ្ឋប្បវេណី

# ក

១. កម្មវត្ថុនៃបណ្តឹង

Eng. Subject-matter of litigation / aim of the complaint

Fr. Object de la demande en justice

គោលបំណង នៃការទាមទាររបស់អ្នកប្តឹង។ គ្រប់បណ្តឹងតាមផ្លូវតុលាការ ទាមទារឱ្យមានកម្មវត្ថុច្បាស់លាស់។ កម្មវត្ថុនៃបណ្តឹងអាចនាំឱ្យដឹងអំពីសញ្ញាណនៃបណ្តឹងបាន។

២. កាតព្វកិច្ច

Eng. obligation

Fr. obligation

ចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា "កូនបំណុល" មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀត ដែលបានកំណត់ហៅថា "ម្ចាស់បំណុល"។

៣.ការកោះហៅ

Eng. summon

Fr. convocation

ការបង្គាប់របស់តុលាការ ដែលតម្រូវឱ្យបុគ្គលណាមួយ ត្រូវតែមកបង្ហាញខ្លួននៅតុលាការតាមការបរិច្ឆេទ ដែលបានកំណត់។ ការកោះហៅអាចធ្វើតាមវិធីបញ្ជូនដីកាកោះ ឬដោយជូនដំណឹងអំពីកាលបរិច្ឆេទ។

៤. ការចាត់ចែងបណ្តោះអាសន្ន

Eng. provisional disposition

Fr. mise en disposition provisoire

ប្រភេទមួយនៃការចាត់ចែងរក្សាការពារ ដើម្បីធានាសិទ្ធិលើបំណុល ដែលគ្មានគោលបំណងសងជាប្រាក់។ ការចាត់ចែងជាបណ្តោះអាសន្នមានពីរប្រភេទ គឺការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុ និងជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន។

៥. ការចាត់ចែងរក្សាការពារ

Eng. preservative relief

Fr. mesures conservatoires

វិធានការ ដែលតុលាការចាត់ចែងជាបណ្តោះអាសន្នតាមពាក្យសុំរបស់បុគ្គលណាមួយ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលនោះ។ ការចាត់ចែងរក្សាការពារមានបីប្រភេទគឺ ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈ(ស្ថានភាព)ជាបណ្តោះអាសន្ន។

# សទ្ទានុក្រមនីតិវិធីរដ្ឋប្បវេណី

៦. ការចូលរួមជួអន្តរាគមន៍

Eng. intervention
Fr. intervention

នីតិវិធី ដែលអនុញ្ញាតឱ្យតតិយជនដែលមានទំនាក់ទំនងនិងមានផលប្រយោជន៍តាមផ្លូវច្បាប់ចូលរួមក្នុងបណ្តឹងដើម្បីជួយភាគីណាមួយក្នុងគោលបំណងការពារផលប្រយោជន៍របស់ខ្លួន។

៧. ការចុះបញ្ជី

Eng. registration
Fr. enregistrement

ការកត់ត្រាចូលក្នុងបញ្ជីផ្លូវការ។

៨. ការជំនុំជម្រះក្តីលើកទី១

Eng. judgement of first instance
Fr. judgement en premier ressort

ការជំនុំជម្រះ ដែលបើកផ្លូវឧទ្ធរណ៍។

៩. ការជំនុំជម្រះសាជាថ្មី

Eng. rehearing / retrial
Fr. révision du procès

ការជំនុំជម្រះសាឡើងវិញតាមការប្តឹងទាមទារចំពោះសាលក្រម ឬសាលដីកាស្ថាពរដោយមូលហេតុថា នីតិវិធីនៃសេចក្តីវិនិច្ឆ័យនោះមានកង្វះខាត ឬមិនប្រក្រតី។

១០. ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង

Eng. revival of litigation proceedings
Fr. reprise d’instance

ដំណើរការនីតិវិធីនៃបណ្តឹង ដោយអ្នកទទួលបន្តដែលមានលក្ខណសម្បត្តិបន្ទាប់ពីមានការផ្អាក ឬព្យួរនីតិវិធីនៃបណ្តឹង។

១១. ការទាញហេតុផលដោយផ្ទាល់មាត់

Eng. oral argument
Fr. débat oral / plaidoirie

ការទាញហេតុផលដោយផ្ទាល់មាត់ សំដៅលើការបង្ហាញអំពីមធ្យោបាយតទល់ ឬការពារខ្លួនអំពីអង្គសេចក្តីដោយផ្ទាល់មាត់ ធ្វើឡើងដោយភាគីនៅចំពោះមុខតុលាការ ក្នុងសវនាការសាធារណៈ។ ការទាញហេតុផលដោយផ្ទាល់មាត់ ជានីតិវិធីចាំបាច់ដែលត្រូវតែធ្វើមុននឹងតុលាការសម្រេចសេចក្តីដោយចេញសាលក្រម។

១២. ការបង្អង់នីតិវិធីបណ្តឹង

Eng. suspension of the litigation proceedings
Fr. suspension du pores / suspension de l’instance

ការតម្កល់មួយអន្លើនូវនីតិវិធីនៃបណ្តឹង ដោយសារមានមូលហេតុមួយចំនួនដូចជា សង្គ្រាម គ្រោះមហន្តរាយធម្មជាតិ រឿងក្តីព្រហ្មទណ្ឌដែលដែលបង្អង់រឿងក្តីរដ្ឋប្បវេណីជាដើម។

**១៣. ការផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹង**

Eng. aid in litigation
Fr. dispense des frais de justice

វិធានការអនុគ្រោះ ដែលតុលាការអនុញ្ញាតដោយដីកាឱ្យពន្យាពេលបង់ ឬអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ប្រដាប់ក្ដី តាមពាក្យសុំរបស់បុគ្គលដែលពុំមានលទ្ធភាពបង់។

**១៤. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជី**

Eng. instrument of registration
Fr. charge d’enregistrement

ការប្រគល់ភារកិច្ច និងការតម្រូវឱ្យចុះបញ្ជី។

**១៥. ការផ្សះផ្សា**

Eng. conciliation
Fr. conciliation

ការសម្រុះសម្រួលគូភាគីឱ្យសះជានឹងគ្នា។

**១៦. ការផ្អាកនីតិវិធីនៃបណ្ដឹង**

Eng. interruption of the proceedings
Fr. interruption de l’instance / interruption du procès

ការព្យួរមួយគ្រាសិននូវនីតិវិធី នៃបណ្ដឹងដោយសារ មានហេតុការណ៍មួយចំនួនដូចជា មរណភាព ការបាត់បង់សមត្ថភាពរបស់ភាគីជាអាទិ៍ ក្នុងគោលបំណងធានាសិទ្ធិរបស់ភាគីចំពោះនីតិវិធី។

**១៧. កាតលក់ដោយបង្ខំ**

Eng. compulsory sale
Fr. ventre force

វិធាន ដែលប្រើប្រាស់ក្នុងនីតិវិធី នៃការអនុវត្តដោយបង្ខំ ដើម្បីលក់វត្ថុដែលរឹបអូសយកប្រាក់ទៅសងម្ចាស់បំណុល តាមលិខិតអនុវត្ត សាល់ក្រមសាលដីកា លិខិតយថាភូត របស់សារការីជាអាទិ៍ (ម.ព ការអនុវត្តដោយបង្ខំ និងលិខិតអនុវត្ត)។ ការលក់ដោយប្ខំត្រូវសម្រេច ដោយដីកាសម្រេចរបស់តុលាការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុល ក្នុងករណីដែលមានលក្ខណ:ត្រឹមត្រូវ ដើម្បីទទួលស្គាល់ពាក្យសុំនោះ។

**១៨. ការលក់សរុប**

Eng. sale as a whole
Fr. vente ar total

វិធាន នៃការលក់អចលវត្ថុដែលរឹបអូស។ វិធានការនេះប្រើប្រាស់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំ សម្រាប់ការលក់ឱ្យស្រេចតែម្ដងនូវអចលនវត្ថុរឹបអូសដែលមានច្រើនក្នុងគោលបំណងលក់ឱ្យបានថ្លៃខ្ពស់ ដើម្បីជាផលប្រយោជន៍ដល់ម្ចាស់បំណុលផង និងកូនបំណុលផង។

**១៩. ការលក់ឡាយឡុង**

Eng. auction sale
Fr. vente aux enchères

ការលក់ដោយដេញថ្លៃនូវវត្ថុ ដែលរឹបអូស។ តាមរយ:ការលក់នេះ បុគ្គលគ្រប់រូបអាចក្លាយជាលទ្ធករនៃវត្ថុ ដែលដាក់លក់ឡាយឡុង កាលណាគេបានឱ្យថ្លៃខ្ពស់ជាងគេ ក្នុងកាលបរិច្ឆេទនៃការលក់ឡាយឡុង។ នៅក្នុងក្រម

នីតិវិធីរដ្ឋប្បវេណី ការលក់ឡាយឡុងអាចធ្វើឡើងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់។

២០. ការអនុវត្តជាបណ្ដោះអាសន្ន
Eng. provisional execution
Fr. exécution provisoire

មធ្យោបាយមួយ ដែលតុលាការអនុញ្ញាតឱ្យដើមចោទ ដែលឈ្នះក្ដីអាចទទួលបានឆាប់នូវផលប្រយោជន៍លើទ្រព្យសម្បត្តិ ដែលសន្មតថាជាកម្មសិទ្ធិរបស់ខ្លួន ទោះបីជាសាលក្រម ឬសាលដីកាពុំទាន់ចូលជាស្ថាពរក៏ដោយ។

២១. ការអនុវត្តជំនួស
Eng. substituted execution
Fr. exécution par substitution

វិធានការនៃការអនុវត្តដោយបង្ខំដែលតុលាការអនុវត្តចេញដីកាសម្រេច អនុញ្ញាតឱ្យតតិយជនបំពេញសកម្មភាពជំនួសកូនបំណុលដោយ ប្រើសោហ៊ុយរបស់កូនបំណុល តាមពាក្យសុំរបស់ម្ចាស់បំណុល។

២២. ការអនុវត្តដោយបង្ខំ
Eng. compulsory execution
Fr. exécution forcée

នីតិវិធីមួយ ដែលអនុញ្ញាតឱ្យបុគ្គលដែលមានសិទ្ធិទាមទារសិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀតធ្វើការទាមទារឱ្យសម្រេចសិទ្ធិនោះ ដោយការអនុវត្តដោយបង្ខំ។ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយតុលាការអនុវត្ត ឬ ដោយអាជ្ញាសាលា។

២៣. កិច្ចសន្យា
Eng. contract
Fr. contrat

កិរិយា ដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។

២៤. កិច្ចសន្យាមជ្ឈត្តកម្ម
Eng. arbitration agreement
Fr. compromis d’arbitrage / contrat d’arbitrage

ការព្រមព្រៀងដែលគូភាគី សម្រេចយកវិវាទរបស់ខ្លួនទៅដោះស្រាយតាមផ្លូវមជ្ឈត្តកម្ម(ម.ព. មជ្ឈត្តករ និងអាជ្ញាកណ្ដាល)។

២៥. កូនបំណុលទី៣
Eng. third party obligor-debtor
Fr. tiers débiteur

កូនបំណុលនៃសិទ្ធិលើបំណុល ដែលនឹងត្រូវរឹបអូសក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ។

២៦. កូនបំណុលនៃការអនុវត្តដោយបង្ខំ
Eng. debtor in compulsory execution / obligor of compulsory execution
Fr. débiteur de l’exécution forée

បុគ្គល ដែលទ្រព្យសម្បត្តិរបស់ខ្លួនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ (ម.ព. ការអនុវត្តដោយបង្ខំ)។

២៧. កោសលវិច័យ

Eng. expert testimony
Fr. expertise

-ប្រតិបត្តិការរបស់អ្នកជំនាញដូចជា គ្រូពេទ្យលេខនាករ (អ្នកជំនាញខាងអក្សរសរសេរដៃ) ជាអាទិ៍ ដែលតុលាការបានចាត់តាំង ដើម្បីពិនិត្យពិចារណាមួយក្នុងគោលបំណងបំភ្លឺតុលាការ។
-នីតិវិធីមួយដែលតាមនោះ ចៅក្រមសុំឱ្យអ្នកឯកទេស បំភ្លឺអំពីចំណុចសំខាន់ខ្លះៗនៃរឿងក្ដីណាមួយ ដែលទាមទារឱ្យអ្នកឯកទេសផ្ដល់មតិដើម្បីបង្គ្រប់ទៅលើបទពិសោធ និង ជំនាញរបស់ចៅក្រមក្នុងការកាត់សេចក្ដី។

២៨. កំណត់ហេតុស្ដីពីការសះជា

Eng. protocol / record of compromise settlement
Fr. accord sur le règlement amiable / procès verbal de conciliation

លិខិតដែលកត់ត្រាអំពីលទ្ធផលនៃការផ្សះផ្សា ដែលភាគីបានព្រមព្រៀងគ្នា និងនាំឱ្យមានការបញ្ចប់រឿងក្ដី។ កំណត់ហេតុស្ដីពីការសះជាមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរដែរ។

២៩. ក្បួនរីតិ៍សាសនា

Eng. rite or ritual
Fr. reite ou rituel

ក្បួនតម្រាអំពីប្រពៃនី ទំនៀមទម្លាប់ ឬបែបបទ ឬពិធីសក្ការបូជាក្នុងសាសនា ឬជំនឿណាមួយ។

៣០. ក្រឡាបញ្ជី

Eng. clerk of court
Fr. greffier

មន្ត្រីតុលាការ ដែលបំពេញមុខងារធានានូវដំណើរការ នៃលេខាធិការដ្ឋានរបស់យុត្តាធិការ។ ក្រឡាបញ្ជីមានតួនាទីច្រើនយ៉ាង តែគេអាចប្រមូលផ្ដុំជាពីប្រភេទគឺៈ
១-ក្នុងឋានៈជាជំនួយការរបស់តុលាការ ក្រឡាបញ្ជីជួយការងារចៅក្រម និងចូលរួមក្នុងគ្រប់កិច្ចនៃនីតិវិធី។
២-ក្នុងឋានៈជាអ្នកថែរក្សាឯកសារ ក្រឡាបញ្ជីជាអ្នកគ្រប់គ្រងថែរក្សាឯកសាររបស់យុត្តាធិការ និងផ្ដល់នូវសម្រង់ ឬឯកសារចម្លងនានា។

៣១. ក្រុមប្រឹក្សាជំនុំជម្រះ

Eng. panel of judges
Fr. formation de jugement

ក្រុមចៅក្រម ដែលជំនុំជម្រះរឿងក្ដីណាមួយនៅតាមសាលាជម្រះក្ដី។
ឧ. ជាគោលការណ៍ ការជម្រះក្ដីនៅសាលាឧទ្ធរណ៍ត្រូវធ្វើឡើង ដោយក្រុមប្រឹក្សាជំនុំជម្រះ ដែលមានចៅក្រម៣នាក់។

# គ ច ឆ

៣២. គោលការណ៍ចំពោះមុខ
Eng. principle of contradiction
Fr. principle du contradictoire

១-សិទ្ធិ ជាមូលដ្ឋានរបស់ភាគីក្នុងការចូលរួមនៅគ្រប់ដំណើរការនៃនីតិវិធីមានជាអាទិ៍ ការបង្ហាញដល់តុលាការនូវឯកសារភស្តុតាងរបស់ភាគីម្ខាង ដែលតុលាការត្រូវតែជូនដំណឹងដល់ភាគីម្ខាងទៀត ដើម្បីយកមកជជែកតទល់គ្នានៅពេលសវនាការ។
២-គោលការណ៍ជាមូលដ្ឋាន នៃដំណើរការរបស់តុលាការ ដែលទាមទារឱ្យមានការជម្រះក្តីដោយធ្វើការកោះហៅ និងសាកសួរជាចាំបាច់។ ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំណោះមុចនៅគ្រប់កាលៈទេសៈ។

៣៣. ចុងចម្លើយ
Eng. defendant
Fr. défendeur / défenderesse

បុគ្គល ដែលត្រូវបានភាគីម្ខាងទៀត (ដើមចោទ) ប្តឹងទៅតុលាការក្នុងរឿងក្តីរដ្ឋប្បវេណី (ម.ព. ដើមចោទ)។

៣៤. ចៅក្រមដែលទទួលការប្រគល់សិទ្ធិ
Eng. assigned non-panel member judge
Fr. juge délégué

ចៅក្រម ដែលត្រូវស្ថិតនៅក្នុងតុលាការណាមួយដែលទទួលការផ្ទេរសិទ្ធិ ពីតុលាការផ្សេងឱ្យបំពេញកិច្ចការអ្វីមួយក្នុងនាមតុលាការ ដែលបានផ្ទេរសិទ្ធិនោះ។ ឧ. តុលាការក្រុងភ្នំពេញ ផ្ទេរសិទ្ធិឱ្យចៅក្រមនៅតុលាការខេត្តបន្ទាយមានជ័យ សាកសួរសាក្សីដែលមានទីលំនៅ នៅខេត្តបន្ទាយមានជ័យនោះ។

៣៥.ចៅក្រមដែលទទួលបញ្ជា
Eng. assigned panel member judge
Fr. juge désigné / juge commis par la formation fu jugement

ចៅក្រមជាសមាជិក នៃក្រុមប្រឹក្សាជំនុំជម្រះដែលទទួលបានភារកិច្ចពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីបំពេញកិច្ចការអ្វីមួយ ក្នុងនាមក្រុមប្រឹក្សាជំនុំជម្រះនោះ។
ឧ. តុលាការអាចឱ្យចៅក្រមទទួលបញ្ជា ធ្វើការសាកសួរសាក្សីចាស់ជរាមានជម្ងឺដែលមិនអាចចូលខ្លួនមកបំភ្លឺតុលាការបាន។

៣៦. ចំណុចវិវាទ
Eng. issues of litigation
Fr. question litigieuse / point en litige

ចំណុចនៃទំនាស់ដែលត្រូវបំភ្លឺ ដើម្បីចេញសាលក្រម។ ចំណុចវិវាទអាចជាចំណុចវិវាទលើអង្គហេតុ ឬ ចំណុច វិវាទលើអង្គច្បាប់។

៣៧. ឆន្ទានុសិទ្ធិ

Eng. on court’s own authority (mere motion ex mer motu)/ discretion

Fr. pouvoir discrétionnaire

១-អំណាច ដែលច្បាប់ប្រគល់ដល់ចៅក្រមឱ្យរើសយកមធ្យោបាយណាមួយ តាមការវាយតម្លៃរបស់ខ្លួនមកដោះស្រាយបញ្ហាណាមួយ។

២-អំណាចរបស់ចៅក្រមក្នុងការធ្វើសកម្មភាពក្នុងនីតិវិធីនៃបណ្ដឹង ដោយមិនបាច់មានពាក្យសុំរបស់ភាគី។

# ជ ញ

៣៨. ជននៅក្រោមហិតូបត្ថម្ភ

Eng. person under \
curatorship

Fr. personne placée sous
curatelle

ជន ដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយត្រូវបានតុលាការដាក់ឱ្យស្ថិតនៅក្រោមការថែទាំដោយហិតូបត្ថម្ភកៈ។

៣៩. ជននៅក្រោមអាណាព្យាបាលទូទៅ

Eng. adult under
guardianship

Fr. majeur sous tutelle

នីតិជនដែលស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនជានិរន្តរ៍ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយត្រូវបានប្រកាសដាក់ឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។

៤០. ជវលេខ

Eng. stenography

Fr. sténographie

ការសរសេររហ័ស វិធីប្រើសញ្ញា ឬគំនូសសម្រាប់កត់ត្រា ឬសរសេរឱ្យបានរហ័សតាមទាន់សំដីដែលគេបាននិយាយ។

៤១. ញាតិពន្ធ

Eng. relatives by affinity

Fr. alliance

ចំណងគតិយុត្តរវាងសហព័ន្ធម្ខាង និងញាតិលោហិតរបស់សហព័ន្ធម្ខាងទៀត។
ឧ. ឪពុកម្តាយក្មេក និងកូនប្រសា បងថ្លៃប្អូនថ្លៃ (ខាងប្តី ឬខាងប្រពន្ធ) ។ល។

៤២. ញាតិលោហិត

Eng. relatives by blood/
consanguinity

Fr. parenté

ញាតិដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុក និងកូន ឬម្តាយ និងកូនជាដើម។

# ដ

៩៣. ដីកាកោះ

Eng. summon
Fr. citation

លិខិតបង្គាប់របស់តុលាការ ដែលតម្រូវឱ្យបុគ្គលណាមួយ ត្រូវតែមកបង្ហាញខ្លួននៅតុលាការតាមកាលបរិច្ឆេទដែលបានកំណត់។

៩៤.ដីកាសម្រេច

Eng. ruling
Fr. ordonnance

ការសម្រេចសេចក្តីដែលតុលាការ ឬចៅក្រមអាចធ្វើដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនមែនជាសាលក្រមទេ។

៩៥.ដើមចោទ

Eng. plaintiff
Fr. demandeur / demanderesse

ភាគី ដែលផ្តួចផ្តើមដាក់ពាក្យបណ្តឹងទៅតុលាការក្នុងរឿងក្តីរដ្ឋប្បវេណី។

# សទ្ទានុក្រមនីតិវិធីរដ្ឋប្បវេណី

# ត ទ

៤៦. តក្កកម្ម

Eng. invention
Fr. invention

ការបង្កើតអ្វីមួយថ្មីមុនអ្នកទាំងពួង។

៤៧. តតិយជន

Eng. third party
Fr. tiers

ជនទីបី ឬជន ដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត។ ជន ដែលមិនមែនជាភាគីក្នុងរឿងក្ដីរដ្ឋប្បវេណី។

៤៨. តម្លៃលក់អប្បបរមា

Eng. minimum sale price
Fr. prix minimal de vente

តម្លៃ ដែលកំណត់ដោយអ្នកវាយតម្លៃសម្រាប់ជាមូលដ្ឋាននៃការដេញថ្លៃ ក្នុងការលក់ដោយបង្ខំ។

៤៩. តាវកាលិក

Eng. prestation / Performance
Fr. prestation

វត្ថុ ឬសកម្មភាព ដែលជាទីតាំង (ឬជាកម្មវត្ថុ) នៃកាតព្វកិច្ច។
ឧ. តាវកាលិករបស់អ្នកទិញ គឺបង់ថ្លៃទៅឱ្យអ្នកលក់ ឯតាវកាលិករបស់អ្នកលក់ គឺប្រគល់វត្ថុទៅឱ្យអ្នកទិញ។
ឧ. ស្រូវ ដែលជនម្នាក់ខ្ចីពីជនម្នាក់ទៀតហៅថា តាវកាលិកនៃការខ្ចី។

៥០. តុលាការ

Eng. court
Fr. juridiction / tribunal

ស្ថាប័នសាធារណៈ ដែលមានអំណាចវិនិច្ឆ័យសេចក្ដីលើរឿងក្ដី។

៥១. តុលាការកំពូល

Eng. supreme court
Fr. cour sprême

តុលាការជាន់ខ្ពស់បំផុត ដែលមានសមត្ថកិច្ចសម្រេចលើបណ្ដឹងសាទុក្ខជាអាទិ៍។

៥២. តុលាការជាន់ខ្ពស់

Eng. higher court
Fr. juridiction supérieure

តុលាការ ដែលមានអំណាចវិនិច្ឆ័យលើបណ្ដឹងឧបាស្រ័យដែលមិនសុចចិត្តនឹងសេចក្ដីសម្រេចរបស់តុលាការជាន់ទាប។

៥៣. តុលាការដើម

Eng. juridiction whose decision being subject to appeal
Fr. juridiction dont la décision faisant l'objet d'un recours

តុលាការដែលចេញសាលដីការដើម ឬសាលក្រមដើមដែលជាប់បណ្ដឹងឧបាស្រ័យ។

៥៤. តុលាការមានសមត្ថកិច្ច

Eng. court having jurisdiction / competent court
Fr. juridiction compétente

តុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យសេចក្តីលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន។

៥៥. តុលាការអនុវត្ត

Eng. execution court
Fr. juridiction d'execution

តុលាការដែលមានអំណាចចាត់ចែងការអនុវត្តដោយបង្ខំ។

៥៦. ទណ្ឌកម្ម

Eng. sanction / punishment
Fr. sanction

តាមក្រមនីតិវិធីរដ្ឋប្បវេណីវិធានការ ដែលត្រូវអនុវត្តចំពោះបុគ្គលណាមួយដែលមិនគោរពប្រតិបត្តិតាមបញ្ញត្តិច្បាប់។

៥៧. ទហនវត្ថុ (ឥន្ធនវត្ថុ)

Eng. combustible
Fr. combustible

វត្ថុសម្រាប់ដុត ឬបញ្ឆេះ ដូចជាធ្យូង ឧស ឧស្ម័ន ប្រេងកាត. ..។

៥៨. ទីសំណាក់

Eng. residence
Fr. résidence

ទីកន្លែង ដែលបុគ្គលម្នាក់ស្នាក់អាស្រ័យនៅជាក់ស្តែង ក្នុងរយៈពេលជាកំណត់ណាមួយដែលមិនមែនជាទីលំនៅ។

ឧ. ឈ្មោះ "ក" មានលំនៅឋាននៅខេត្តតាកែវ បានជួលផ្ទះនៅភ្នំពេញដើម្បីរៀន។ ផ្ទះនៅភ្នំពេញនេះហៅថា ទីសំណាក់។

៥៩. ទំនាក់ទំនងគតិយុត្ត

Eng. legal relationship
Fr. rapports juridiques

ចំណងកើតឡើងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ តាមរយៈកិច្ចគតិយុត្ត ឬបញ្ញត្តិច្បាប់។

# ន

៦០. នត្ថិភាព
Eng. non-existence
Fr. inexistence

ភាវៈគ្មាន ឬភាពនៃអ្វីៗដែលមិនមាន។

៦១. នីតិបុគ្គល
Eng. juridical person / legal person / artificial
Fr. personne morale

ក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។
ឧ. សមាគម ក្រុមហ៊ុន ។ល។

៦២. នីតិវិធីដាស់តឿន
Eng. demand procedure
Fr. procédure de mise en demeure

នីតិវិធីពិសេសមួយនៃនីតិវិធីរដ្ឋប្បវេណី ដែលអនុញ្ញាតឱ្យម្ចាស់បំណុល អាចទទួលបាននូវលិខិតអនុវត្ត។

៦៣. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
Eng. preparatory procedure for oral argument
Fr. préparation à la plaidoirie

ដំណាក់កាលមួយនៃនីតិវិធីរដ្ឋប្បវេណី ដែលក្នុងនោះ តុលាការត្រូវរៀបចំសេចក្តីអះអាងរបស់គូភាគីដែលបំភ្លឺចំណុចវិវាទនៃរឿងក្តី និង រៀបចំភស្តុតាង ដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ។

៦៤. នីតិវិធីនៃការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប
Eng. summary procedure for enforcement of pledge
Fr. procédure sommaire de réalisation du gage

វិធានការមួយនៃនីតិវិធីអនុវត្តដោយបង្ខំ ដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុដាក់ពាក្យសុំឱ្យសាលាដំបូង ដែលមានសមត្ថកិច្ចនៃទីកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ចេញដីកាសម្រេច អនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះមកសងផ្ទាល់តែម្តង។

៦៥. នីតិវិធីសង្ខេប
Eng. summary procedure
Fr. procédure sommaire / procédure à jour fixe

នីតិវិធីមួយ សម្រាប់ដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ចំពោះរឿងក្តីដែលមានទឹកប្រាក់តិច (ទឹកប្រាក់តិចជាងមួយលានរៀល) ។

# សទ្ទានុក្រមនីតិវិធីរដ្ឋប្បវេណី

# ប

៦៦. បដិទាន

Eng. restitution
Fr. restitution

ការស្តារស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ (តាមសេចក្តីសម្រេចរបស់តុលាការ)។
ឧ. ម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ ឬការប្រើប្រាស់ ឬការថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុ ដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុ ដែលម្ចាស់បំណុលបានបង់ ឬបង្វិលសងវត្ថុ ដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងបានតាមពាក្យសុំរបស់កូនបំណុល។

៦៧. បណ្តឹងជាន់គ្នា

Eng. double suit
Fr. double action

បណ្តឹង ដែលមានកម្មវត្ថុដូចគ្នានឹងបណ្តឹង ដែលតុលាការកំពុងចាត់ការ។

៦៨. បណ្តឹងជំទាស់

Eng. appeal against court ruling
Fr. appel contre les ordonnances

បណ្តឹងឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់ (ដែលជាតុលាការនៃបណ្តឹងជំទាស់) ដើម្បីទាមទារ ឱ្យលុបចោល ឬផ្លាស់ប្តូរដីកាសម្រេចដើម។

៦៩. បណ្តឹងជំទាស់

Eng. challenge of a judge clerk
Fr. récusation d’un magistrat ou d’un greffier

បណ្តឹង សុំមិនឱ្យចៅក្រម ឬក្រឡាបញ្ជីណាម្នាក់អនុវត្តមុខការរបស់ខ្លួន ក្នុងករណីមានកាលៈទេសៈ ដែលអាចបណ្តាលឱ្យមានការលម្អៀងរបស់ចៅក្រម ឬក្រឡាបញ្ជីនោះ។

៧០. បណ្តឹងតប

Eng. cross action / counter claim
Fr. demande reconventionnelle

បណ្តឹងសាត្រឡប់ របស់ចុងចម្លើយចំពោះដើមចោទ។ ជាទូទៅ ចុងចម្លើយអាចប្តឹងតបរហូតដល់ពេលចប់ការទាញហេតុផល ដោយផ្ទាល់មាត់បាន លុះត្រាតែកម្មវត្ថុនៃបណ្តឹងតបនោះទាក់ទងនឹងការទាមទារ ដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬជាមធ្យោបាយការពារខ្លួនសម្រាប់បណ្តឹងដើម។

៧១. បណ្តឹងទាមទារប្រមូលបំណុល

Eng. action for collection
Fr. action en recouvrement

បណ្តឹងរបស់ម្ចាស់បំណុលដាក់ជូនទៅតុលាការទាមទារឱ្យកូនបំណុលទីពផ្តល់តាវកាលិក ដែលទាក់ទងទៅនឹងសិទ្ធិលើបំណុល ដែលត្រូវបានរឹបអូសក្នុងករណីដែលកូនបំណុលទីពមិនព្រមសងតាមការប្រមូលបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត។

៧២. បណ្ដឹងទាស់
Eng. Petition to set aside default judgment
Fr. opposition

ផ្លូវតវ៉ា ដែលបើកសិទ្ធិឱ្យភាគីដែលមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទ ប្ដឹងទៅតុលាការដែលបានចេញសាលក្រមឱ្យលើកយករឿងនេះមកចាត់ការឡើងវិញ តាមនីតិវិធីត្រឹមពេលវត្តមានកើតឡើង បន្ទាប់ពីបានទទួលសាលក្រមកំបាំងមុខ ដោយមានមូលហេតុមិនអាចព្យាករណ៍បាន ឬមានមូលហេតុមិនអាចចៀសវាងបាន។

៧៣. បណ្ដឹងផាត់ចោល
Eng. challenge of expert
Fr. récusation d'un expert

ផ្លូវតវ៉ា ដែលបើកសិទ្ធិឱ្យភាគីប្ដឹងផាត់ចោលមិនឱ្យអ្នកជំនាញណាមួយ ធ្វើកោសលវិច័យ ដោយមានមូលហេតុរារាំងសច្ចភាពនៃការធ្វើកោសលវិច័យ។

៧៤. បណ្ដឹងសាទុក្ខ
Eng. appeal to the supreme court
Fr. pourvoi en cassation

ប្រភេទមួយនៃបណ្ដឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលដីកាចុងក្រោយ ដែលត្រូវបានជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍ ឬសាលដីកាចុងក្រោយ ដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី១ តាមបញ្ញត្តិច្បាប់ពិសេស ឬសាលក្រមចុងក្រោយ ដែលបានជំនុំជម្រះលើកទី១ ដោយសាលាដំបូងនៅក្នុងករណី ដែលភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍ ប៉ុន្តែរក្សាទុកនូវសិទ្ធិប្ដឹងសារទុក្ខ។

៧៥. បណ្ដឹងអង្គសេចក្ដី
Eng. suit in principal case / suit on merits
Fr. demande pour le jugement sur le fond

ពាក្យ ទាមទាររបស់ភាគីណាមួយ ដើម្បីឱ្យតុលាការសម្រេចសេចក្ដីលើអង្គសេចក្ដី។
(ម.ព អង្គសេចក្ដី)

៧៦. បណ្ដឹងឧទ្ធរណ៍
Eng. appeal to the appellate court
Fr. appel

ប្រភេទនៃបណ្ដឹងឧបាស្រ័យ ចំពោះសាលក្រមនៃតុលាការជំនុំជម្រះលើកទី១ ទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍។

៧៧. បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ
Eng. incidental appeal to the appellate court
Fr. appel incident

ពាក្យសុំរបស់ចុងបណ្ដឹងឧទ្ធរណ៍ ដែលប្ដឹងជាមួយនឹងបណ្ដឹងឧទ្ធរណ៍ របស់ដើមបណ្ដឹងឧទ្ធរណ៍ ដើម្បីផ្លាស់ប្ដូរសាលក្រម នៃការជំនុំជម្រះលើកទៅ១ សម្រាប់ជាផលប្រយោជន៍របស់ខ្លួន ទោះបីជាសិទ្ធិឧទ្ធរណ៍របស់ខ្លួនបានរលត់ហើយក៏ដោយ។ ឧ. ដើមចោទ ទាមទារ១០០ តែតុលាការទទួលស្គាល់តែ៧០។ ចុងចម្លើយបានប្ដឹងឧទ្ធរណ៍ករណីនេះ ដើមចោទអាចប្ដឹងសុំទាមទារឱ្យតុលាការនៃបណ្ដឹងឧទ្ធរណ៍ ទទួលស្គាល់ទឹកប្រាក់ចំនួន៣០ទៀត ដែលជាផលប្រយោជន៍របស់ខ្លួន។

៧៨. បណ្តឹងឧបាស្រ័យ
Eng. appeal
Fr. recours

បណ្តឹងតវ៉ារបស់ភាគី ដែលពុំយល់ស្របជាមួយសេចក្តីសម្រេចណាមួយ (សាលក្រម សាលដីកា ដីកាសម្រេច) របស់ចៅក្រម ឬតុលាការ ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម។

៧៩. បទដ្ឋានគតិយុត្ត
Eng. law and regulation / legal norm
Fr. norme juridique / règle de droit

វិធានច្បាប់ ដូចជា ច្បាប់ និងបទបញ្ជាផ្សេងៗ ដែលបានបង្កើតឡើងដោយរដ្ឋ។

៨០. បទអាជ្ញា
Eng. criminal offence
Fr. infraction

អំពើ ដែលនាំឱ្យខូចសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ដែលបញ្ញត្តដោយច្បាប់ព្រហ្មទណ្ឌ។

៨១. បុគ្គលអសមត្ថភាព ឬ អសមត្ថជន
Eng. perso lacking capacity
Fr. incapable

បុគ្គល ដែលមិនអាចធ្វើសកម្មភាពតាមផ្លូវច្បាប់ពេញលេញដោយខ្លួនឯងបាន។ តាមក្រមនីតិវិធីរដ្ឋប្បវេណី មានន័យថា បុគ្គល ដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង។

៨២. ប្រាតិភោគលើប្រាក់ប្រដាប់ក្តី
Eng. security fo court costs
Fr. sûreté sur les frais de justice

ការដាក់ទ្រព្យ ដើម្បីធានាប្រាក់ប្រដាប់ក្តីតាមការស្នើសុំ របស់ចុងចម្លើយ ដោយមូលហេតុដើមចោទមិនមានលំនៅឋាន ទីស្នាក់ការ ឬទីកន្លែងអាជីវកម្ម នៅព្រះរាជាណាចក្រកម្ពុជា។

៨៣. ប្រាក់ប្រដាប់ក្តី
Eng. court fees- costs
Fr. frais de justice

ប្រាក់ពន្ធ ឬសោហ៊ុយ ដែលភាគីត្រូវបង់សម្រាប់ចាត់ការរឿងក្តីរបស់ខ្លួន ទៅតុលាការតាមបញ្ញត្តិច្បាប់។ ប្រាក់ប្រដាក់ក្តីរួមមាន ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តីភាគី។

៨៤. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ
Eng. court costs other than filing fee
Fr. frais de justice non fiscaux / frais non compris dans les dépens

ប្រាក់ប្រដាប់ក្តីមួយប្រភេទ ដែលភាគីត្រូវបង់នូវចំនួនចាំបាច់ ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង បញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេងៗ តាមនីតិវិធីក្នុងបណ្តឹង។

៨៥. ប្រាក់ប្រដាប់ក្ដីភាគី
Eng. party’s costs
Fr. dépens à la charge des parties

ប្រាក់ប្រដាប់ក្ដីមួយប្រភេទ ដែលកំណត់ដោយតុលាការសម្រាប់ថ្លៃធ្វើលិខិតបណ្ដឹង លិខិតពាក្យសុំសោហ៊ុយធ្វើដំណើរ ឬសោហ៊ុយផ្សេងៗ។

៨៦. ប្រាក់ពិន័យ
Eng. fine
Fr. amende

ទណ្ឌកម្មជាប្រាក់ ដែលបញ្ញត្តិឡើងដោយច្បាប់រដ្ឋប្បវេណី ឬនីតិវិធីរដ្ឋប្បវេណី ហើយដែលត្រូវប្រកាសឡើងដោយតុលាការផ្នែករដ្ឋប្បវេណី នៅក្នុងករណី ដែលមានការបំពានច្បាប់នេះ។

៨៧. ផលប្រយោជន៍សាធារណៈ
Eng. public interest
Fr. intérêt public

ផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋ នឹងសង្គម។
ឧ. ស្ពាន ថ្នល់ បម្រើផលប្រយោជន៍សាធារណៈ។

៨៨. ផលុបភោគ
Eng. usufruct
Fr. usufruit

សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិអ្នកដទៃ ក្នុងអំឡុងពេលមានកំណត់មួយ ដែលមិនឱ្យលើកពីមួយជីវិតរបស់ផលុបភោគី។

៨៩. ពង្សាវលី
Eng. family tree
Fr. arbre généalogique

តារាងព័ណ៌នា អំពីទំនាក់ទំនងរវាងសមាជិកទាំងអស់នៃគ្រួសារ រាប់ពីបុព្វជន រហូតដល់បច្ឆាជន។

៩០. ពន្ធដាក់ពាក្យសុំ
Eng. filing fee
Fr. frais d'enregistrement

ប្រាក់ប្រដាក់ក្តីមួយប្រភេទ ដែលត្រូវបង់នៅពេលដាក់បណ្តឹងទៅតុលាការ។

៩១. ភស្តុតាង
Eng. evidence
Fr. preuve

តឹកតាងជាលាយលក្ខណ៍អក្សរ ឬមិនមែនជាលាយលក្ខណ៍អក្សរ ដែលជាមូលដ្ឋាននៃការសម្រេចសេចក្តីរបស់តុលាការ។

៩២. ភាគី
Eng. party
Fr. partie

បុគ្គល ដែលស្នើសុំឱ្យតុលាការ ដោះស្រាយវិវាទរបស់ខ្លួននឹងបុគ្គលម្ខាងទៀត ដែលមានការពាក់ព័ន្ធ។
ឧ. នៅសាលាដំបូង ភាគីជាដើមចោទ ឬចុងចម្លើយ។ នៅសាលាឧទ្ធរណ៍ ភាគីជាដើមបណ្តឹងឧទ្ធរណ៍ ឬចុងបណ្តឹងឧទ្ធរណ៍។ នៅតុលាការកំពូល ភាគីជាដើមបណ្តឹងសារទុក្ខ ឬចុងបណ្តឹងសារទុក្ខ។ នៅក្នុងរឿងក្តីនៃការអនុវត្តដោយបង្ខំ ភាគីជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត។

៩៣. មជ្ឈត្តកម្ម
Eng. arbitration
Fr. arbitrage

វិធីដោះស្រាយវិវាទដោយមជ្ឈត្តករ ហើយសេចក្ដីសម្រេចរបស់មជ្ឈត្តករចងភាគីឱ្យអនុវត្តតាម (ម.ព. មជ្ឈត្តករ)។

៩៤. មជ្ឈត្តករ
Eng. arbitrator
Fr. arbitre

បុគ្គល ដែលជាអាជ្ញាកណ្ដាល ទទួលភារកិច្ចតាមកិច្ចសន្យា ដើម្បីដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្ម។

៩៥. មតកជន
Eng. deceased
Fr. défunt

ជន ដែលបានបាត់បង់ជីវិតទៅហើយ។

៩៦. មតិក
Eng. estate
Fr. héritage / hérédité

ទ្រព្យសម្បត្តិទាំងឡាយ ដែលបុគ្គលម្នាក់ (មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់។
ឧ. ឈ្មោះ “ក” បានស្លាប់ ហើយបន្សល់ជាផ្ទះសម្បែង ស្នាដៃនិពន្ធ។

៩៧. មធ្យោបាយការពារ
Eng. defensive measures
Fr. moyens de la défense

ការលើកអំពីអង្គហេតុ ឬអង្គច្បាប់ និងការដាក់ភស្តុតាងដោយចុងចម្លើយ (ឬចុងបណ្ដឹងឧទ្ធរណ៍) ដើម្បីជាសំអាងដល់ការការពាររបស់ខ្លួន។

៩៨. មធ្យោបាយតទល់
Eng. offensive measures
Fr. moyens de la demande

ការលើកអំពីអង្គហេតុ ឬអង្គច្បាប់ និងការដាក់ភស្តុតាងដោយដើមចោទ (ឬដើមបណ្ដឹងឧទ្ធរណ៍) ដើម្បីជាសំអាងដល់ការទាមទាររបស់ខ្លួន។

៩៩. មូលដ្ឋាននៃសាលក្រម
Eng. grounds of judgment
Fr. motif du jugement

មូលហេតុជាមូលដ្ឋាន នៃការចេញសាលក្រមរបស់តុលាការ។

១០០. មូលបត្រឥណទេយ្យជួញដូរបាន (ឧបករណ៍អាចជួញដូរបាន)
Eng. negotiable instrument
Fr. valeurs mobilières

១-តាមក្រមនីតិវិធីរដ្ឋប្បវេណី មានន័យថា មូលបត្រ ដែលតំណាងផលប្រយោជន៍ (សិទ្ធិ) ជាទ្រព្យសម្បត្តិ ហើយដែលការផ្ទេរ ឬការអនុវត្តនូវសិទ្ធិនេះ ធ្វើតាមមូលបត្រ។
២-តាមច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មានន័យថា ប័ណ្ណ ដែលផ្សាយចេញពីរដ្ឋ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនវិនិយោគ ដើម្បីខ្ចីបុលប្រាក់ពីសាធារជនមានរយៈពេលកំណត់ និងអត្រាការប្រាក់ច្បាស់លាស់ គឺជាប័ណ្ណតំណាងឥណទេយ្យ (តំណាងបំណុលត្រូវទារ) ដែលអ្នកកាន់អាចយកទៅជួញដូរបាននៅលើទីផ្សារមួយគ្រប់គ្រងដោយច្បាប់។ មូលបត្រឥណទេយ្យមាន ប័ណ្ណរតនាគារ សញ្ញាប័ណ្ណ ប័ណ្ណបេឡា ។ល។

១០១. មូលប្បទានបត្រ
Eng. check
Fr. chèque

មូលបត្រជួញដូរបានមួយប្រភេទ ដែលតាមនោះបហារីក (អ្នកចេញបញ្ជា) ចុះហត្ថលេខាបញ្ជាដោយឥតលក្ខខណ្ឌទៅធនាគារ (បហារិត) ឱ្យផ្តល់ទឹកប្រាក់ជាក់លាក់មួយចំនួន ទៅអ្នកកាន់មូលបត្រនោះ។

១០២. មូលសាលក្រម
Eng. original judgment
Fr. minute du jugement

ច្បាប់ដើមនៃលិខិតសាលក្រម។

១០៣. មេធាវី
Eng. lawyer / advocate
Fr. avocat

ជន ដែលជាសមាជិកនៃគណៈមេធាវី ផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗ ក្នុងវិស័យគតិយុត្ត តំណាងឱ្យកូនក្តី ឬការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី (ពាក្យចាស់ហៅថា ស្នាក្តី)។

១០៤. មោឃភាព
Eng. nullity
Fr. nullité

១-ភាពពុំមានអានុភាពតាមផ្លូវច្បាប់ នៃសកម្មភាពគតិយុត្ត ដែលផ្ទុយនឹងបញ្ញត្តិអំពីនីតិវិធីនៃបណ្តឹង។
២-ទណ្ឌកម្ម ដែលប្រកាសដោយចៅក្រម លុបបំបាត់ចោលជាប្រតិសកម្មនូវលិខិតគតិយុត្តមិនបានបំពេញលក្ខខណ្ឌ ដែលច្បាប់កំណត់ ឬសកម្មភាពណាមួយ ដែលផ្ទុយពីនីតិវិធីនៃច្បាប់។

១០៥. ម្ចាស់បំណុល
Eng. creditor
Fr. créancier

បុគ្គល ដែលមានសិទ្ធិឥណទេយ្យ (សិទ្ធិលើបំណុល)។

១០៦. ម្ចាស់បំណុលនៃការអនុវត្ត
Eng. creditor in execution
Fr. créancier de l’exécution

ភាគី ដែលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ (ម.ព. ការអនុវត្តដោយបង្ខំ)។

# រ លូ ខ

១០៧. រូបមន្តអនុវត្ត
Eng. execution clause
Fr. formule exécutoire

រូបមន្ត ដែលចុះលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអនុញ្ញាឱ្យបុគ្គលដែលមានផលប្រយោជន៍ធ្វើការទាមទារការអនុវត្តដោយបង្ខំ

១០៨. រូបមន្តអនុវត្តពិសេស
Eng. special execution clause
Fr. formule exécutoire spéciale

រូបមន្តអនុវត្ត ដែលត្រូវបានផ្តល់ក្នុងករណី ដែលក្ខខណ្ឌនៃការអនុវត្តដោយបង្ខំត្រូវបានបំពេញ ឬពេលកំណត់មិនពិតប្រាកដនៃការអនុវត្តដោយបង្ខំបានមកដល់ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយបុគ្គលផ្សេងក្រៅពីភាគី ដែលត្រូវបានសរសេរលើលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលការផ្តល់រូបមន្តអនុវត្ត ដែលមានសរសេរនូវហេតុការណ៍នោះ។

១០៩. រូបទ្រព្យ
Eng. tangible property
Fr. bien corporel

ទ្រព្យ ដែលមានរូបជាក់ស្តែង ដូចជា រថយន្ត ផ្ទះ ។ល។

១១០. រូបវន្តបុគ្គល
Eng. natural person
Fr. personne physique

មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។
(ម.ព. នីតិបុគ្គល)។

១១១. រូបិយាណត្តិ
Eng. bill fo exchange
Fr. traite / lettre de change

មូលបត្រមួយប្រភេទ ដែលហារ៉កប្រើប្រាស់បង្គាប់បញ្ជាទៅបហារិត ឱ្យផ្តល់ទឹកប្រាក់ជាក់លាក់មួយចំនួន នៅក្នុងកាលបរិច្ឆេទណាមួយទៅបុគ្គលទីពដែលហៅថា គាហក:។

១១២. លិខិតយថាភូត
Eng. authentic deed
Fr. acte authentique

លិខិតធ្វើឡើងតាមរូបមន្តច្បាប់ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី។

១១៣. លិខិតអនុវត្ត
Eng. title of execution
Fr. acte exécutoire

ឯកសារផ្លូវការ ដែលជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំមាន សាលក្រម ឬសាលដីកា និងដីកាសម្រេច អនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករជាដើម។

១១៤. លំនៅឋាន
Eng. domicile
Fr. domicile

កន្លែងដែលជាទីតាំង នៃជីវភាពរស់នៅជាអចិន្ត្រៃយ៍របស់បុគ្គលម្នាក់ៗ។

១១៥. វិធានការបណ្ដោះអាសន្ន

Eng. provisional measure
Fr. mesures conservatoires

វិធានការ ដែលមានគោលដៅការពារសិទ្ធិរបស់ភាគី ក្នុងករណីមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដោយសារមានហេតុដូចខាងក្រោម៖
-មានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល នៃការអនុវត្ត។
-អាចនឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិបុគ្គល។

១១៦. វិធានបង្ខំដោយប្រយោល

Eng. indirect enforcement
Fr. exécution indirecte

វិធានការនៃការអនុវត្តដោយបង្ខំ ដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង់ប្រាក់ធានាការអនុវត្តកាតព្វកិច្ច តាមពាក្យសុំរបស់ម្ចាស់បំណុល។

១១៧. វិនិច្ឆ័យ

Eng. judge / hear / trial
Fr. juger / statuer

ជំនុំជម្រះក្ដី។

១១៨. វិវាទរដ្ឋប្បវេណី

Eng. civil dispute
Fr. litige civil

វិវាទ ដែលកើតឡើងរវាងបុគ្គល និងបុគ្គលក្នុងទំនាក់ទំនងផ្នែករដ្ឋប្បវេណី។
ឧ. វិវាទកើតឡើងចេញពីទំនាក់ទំនងទ្រព្យសម្បត្តិ ឬទំនាក់ទំនងញាតិ ឬទំនាក់ទំនងប្រចាំថ្ងៃជាដើម។

# ស ហ

១១៩. សក្ខីភាពក្លែងក្លាយ
Eng. perjury / false evidence
Fr. faux témoignage

ចម្លើយភូតកុហករបស់សាក្សី ដែលបានស្បថនៅចំពោះមុខតុលាការរួចហើយ។

១២០. សច្ចានុមតិ
Eng. ratification
Fr. ratification

១-ការយល់ព្រមទទួលស្គាល់ ដែលមានអានុភាពប្រតិសកម្ម។
ឧ. ក្មេងម្នាក់ (១៧ឆ្នាំ) ធ្វើកិច្ចសន្យាមួយ កិច្ចសន្យានោះមិនពេញលក្ខណៈច្បាប់ទេ។ តែបើក្មេងនោះផ្ដល់សច្ចានុមតិ (ការផ្ដល់ការយល់ព្រម) លើកិច្ចសន្យានោះ ក្រោយពេលវាធំពេញវ័យ (១៨ឆ្នាំ) កិច្ចសន្យានោះក្លាយជាកិច្ចសន្យាពេញលក្ខណៈច្បាប់។
២-ការទទួលស្គាល់របស់ភាគីចំពោះសកម្មភាពបណ្ដឹង ដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលខ្វះសិទ្ធិតំណាងដោយអាណត្តិ ហើយការទទួលស្គាល់នោះ ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង។

១២១. សញ្ញាណ
Eng. description
Fr. notion

អត្ថសញ្ញាណនិងសញ្ញាផ្សេងៗ។
(ម.ព. អត្តសញ្ញាណ)

១២២. សន្តតិកម្ម
Eng. succession
Fr. succession

ការផ្ទេរនូវបេតិកភ័ណ្ឌរបស់មតកជន ឱ្យទៅអ្នករស់ម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។

១២៣. សមត្ថកិច្ចជំនុំជម្រះ
Eng. trial jurisdiction
Fr. compétence juridictionnelle

អំណាចស្របច្បាប់ របស់តុលាការក្នុងការជំនុំជម្រះក្ដី។

១២៤. សមត្ថកិច្ចផ្ដាច់មុខ
Eng. exclusive jurisdiction
Fr. compétence exclusive

អំណាច ដែលផ្ដល់ឱ្យតុលាការណាមួយជាកំណត់ក្នុងការទទួលបណ្ដឹងវិនិច្ឆ័យរឿងក្ដីចេញសាលក្រម ឬសាលដីកា។

១២៥. សមត្ថភាពភាគី
Eng. capacity to be party
Fr. capacité d’ester en partie

សិទ្ធិ និងកាតព្វកិច្ចតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ផ្សេងៗទៀត ដែលបានកំណត់ឱ្យបុគ្គលណាមួយ អាចជាដើមចោទ ឬ ចុងចម្លើយ។

១២៦. សមូហវិធី
Eng. concentration
Fr. concentration

ការធ្វើឡើងនៅពេលតែមួយ និងដោយប្រមូលផ្តុំ។
ឧ. ការសាកសួរសាក្សី ឬគូភាគី អាចធ្វើតាមរបៀបសមូហវិធីបាន។

១២៧. សវនាការសាធារណៈ
Eng. public hearing
Fr. audience publique

-នីតិវិធីជំនុំជម្រះ ដែលតុលាការស្តាប់ការអះអាងរបស់គូភាគី សួរដេញដោល ស្តាប់សេចក្តីសន្និដ្ឋាននានា និងសម្រេចសេចក្តី ដោយបើកចំហសម្រាប់សាធារណជន។
-ការទាញហេតុផលដោយផ្ទាល់មាត់ និងការសម្រេចសេចក្តី ដោយបើកចំហដោយសាធារណៈ តាមគោលការណ៍ចំពោះមុខ និងការប្រកាសសាលក្រមដែលត្រូវធ្វើជាសាធារណៈ។

១២៨. សហបណ្តឹង
Eng. joint litigation
Fr. action conjointe

បណ្តឹងមួយប្រភេទ ដែលមានដើមចោទ ឬ ចុងចម្លើយច្រើននាក់។

១២៩. សហបណ្តឹងចាំបាច់
Eng. necessary joint litigation
Fr. action con jointe nécessaire

ករណី ដែលសិទ្ធិ ឬកាតព្វកិច្ច ជាកម្មវត្ថុនៃបណ្តឹង នឹងត្រូវសម្រេចជាស្ថាពរបាន លុះត្រាតែមានការចូលរួមពីអ្នកធ្វើសហបណ្តឹងទាំងអស់។

១៣០. សហបណ្តឹងធម្មតា
Eng. ordinary jont litigation
Fr. action conjointe ordinaire

ករណី ដែលបុគ្គលម្នាក់ៗនៃសហបណ្តឹងមានសិទ្ធិចាត់ចែងសិទ្ធិ ឬកាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងដាច់ដោយឡែកពីគ្នាបាន។

១៣១. សហព័ន្ធ
Eng. spouse
Fr. conjoint(e)

ប្តី ឬប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធ ដែលទទួលបានឋានៈជាសហព័ន្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

១៣២. សាក្សី
Eng. witness
Fr. témoin

បុគ្គល ដែលត្រូវតុលាការកោះហៅមកសាកសួរ នូវហេតុការណ៍ ដែលមានប្រយោជន៍ដល់ការវិនិច្ឆ័យរឿងក្តី។

១៣៣. សាលក្រម
Eng. judgment
Fr. jugement

សេចក្តីសម្រេច របស់តុលាការជាន់ទាបមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ ដែលច្បាប់បានកំណត់ដោយផ្អែកតាមការទាញហេតុផលផ្ទាល់

១៣៤. សាលក្រមកំបាំងមុខ
Eng. default judgment
Fr. jugement far défaut

សាលក្រម ដែលតុលាការសម្រេច ដោយគ្មានវត្តមានរបស់ភាគីដើមចោទ ឬភាគីចុងចម្លើយ ឬអ្នកតំណាងស្របច្បាប់របស់ដើមចោទ ឬចុងចម្លើយ។

១៣៥. សាលក្រមចុងក្រោយ
Eng. final judgment
Fr. jugement sur le fond

សេចក្តីសម្រេចបញ្ចប់ការវិនិច្ឆ័យដល់អង្គសេចក្តីទាំងមូល ឬមួយផ្នែក ដោយផ្អែកលើលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីសាលក្រមចុងក្រោយមានច្រើនប្រភេទ ដូចជា សាលក្រមលើកចោលពាក្យបណ្តឹង សាលក្រមច្រានចោលការទាមទារ សាលក្រមទទួលស្គាល់ការទាមទារជាអាទិ៍។

១៣៦. សាលក្រមរបៀប
Eng. interlocutory judgment
Fr. jugement avant dire droit / jugement interlocutoire

សេចក្តីសម្រេចមុនអង្គសេចក្តីរបស់តុលាការនៅក្នុងដំណាក់កាលណាមួយនៃនីតិវិធី ដែលសម្រេចអំពីវិវាទ ឬហេតុណាមួយ (បញ្ហាបឋម ឬបន្ទាន់បន្សំ) ក្នុងគោលដៅសម្រួលនីតិវិធីនៃបណ្តឹង។

១៣៧. សាលដីកា
Eng. judgment
Fr. arrêt

សេចក្តីសម្រេច របស់សាលាជម្រះក្តីជាន់ខ្ពស់ (សាលាឧទ្ធរណ៍ តុលាការកំពូល) ដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ ដែលច្បាប់បានកំណត់ ដដោយផ្អែកតាមការទាញហេតុផលដោយផ្ទាល់មាត់។

១៣៨. សាលាដំបូង
Eng. court of the first instance
Fr. tribunal de première

សាលជម្រះក្តីជាន់ទាប (តុលាការខេត្ត ក្រុង) ដែលមានសមត្ថកិច្ច ទទួលស្របច្បាប់នូវពាក្យបណ្តឹង និងវិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ។

១៣៩. សិទ្ធិ
Eng. right
Fr. droit

អំណាច ទទួលស្គាល់តាមផ្លូវច្បាប់ ដែលអាចទទួលការពារ ឬទាមទារនូវផលប្រយោជន៍ណាមួយ។ ឧ. សិទ្ធិប្តឹងទៅតុលាការចំពោះវិវាទរដ្ឋប្បវេណី ឬសិទ្ធិទាមទារអ្វីមួយ។

១៤០. សិទ្ធិជាអាទិភាព
Eng. right to preference
Fr. droit de préférence

សិទ្ធិរបស់ម្ចាស់បំណុល ដែលទទួលការសងបំណុលមុនម្ចាស់បំណុលផ្សេងៗទៀត។

១៤១. សិទ្ធិជួយអចិន្ត្រៃយ៍
Eng. perpetual lease right / long lease right
Fr. droit sur le bail emphytéotique / emphytéose

សិទ្ធិជួយអចលនវត្ថុ ដែលមានរយៈពេលចាប់ពី ១៥ឆ្នាំឡើងទៅ។

១៤២. សិទ្ធិតំណាង
Eng. agent authority
Fr. pouvoir du mandataire

សិទ្ធិ ដែលអ្នកតំណាងអាចធ្វើកិច្ចការជំនួសម្ចាស់សិទ្ធិ ហើយបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិ។

១៤៣. សិទ្ធិតំណាងដោយអាណត្តិ
Eng. authority of appointed agent
Fr. pouvoir du mandataire

សិទ្ធិរបស់អ្នកតំណាង ដែលទទួលបានតាមកិច្ចសន្យាអាណត្តិ ដើម្បីធ្វើសកម្មភាពក្នុងនីតិវិធីចំពោះមុខតុលាការក្នុងនាមម្ចាស់សិទ្ធិ។

១៤៤. សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិក
Eng. real right
Fr. droit réel

សិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។

១៤៥. សិទ្ធិប្រាតិភោគ
Eng. security rights
Fr. droit de sûreté

ម.ព ប្រាតិភោគ។

១៤៦. សិទ្ធិលើការបញ្ចាំ
Eng. pledge
Fr. droit de sûreté

សិទ្ធិកាន់កាប់វត្ថុ ដែលបានពីកូនបំណុល ឬ តតិយជនដើម្បីធានាសិទ្ធិ លើបំណុលរបស់ខ្លួន និងទទួលសំណង ចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។

១៤៧. សិទ្ធិលើបំណុល
Eng. claim
Fr. droit de créance / droit personnel

សិទ្ធិទាមទាររបស់បុគ្គលម្នាក់ (ម្ចាស់បំណុល) ចំពោះបុគ្គលម្នាក់ទៀត (កូនបំណុល) ឱ្យផ្តល់នូវតាវកាលិកអ្វីមួយ។

១៤៨. សេចក្តីថ្លែងការណ៍
Eng. statement
Fr. déclaration

សេចក្តីអះអាងដោយវាចាក្តី ដោយលាយលក្ខណ៍អក្សរក្តី ដែលរៀបរាប់អំពីអង្គហេតុ អំពីគោលបំណងណាមួយ។

១៤៩. សំណើទិញ
Eng. offer to buy
Fr. offre d'achat

ការស្នើជាតម្លៃ ដែលធ្វើឡើងដោយអ្នកចូលរួមដេញថ្លៃ ក្នុងការលក់ឡាយឡុង (អ្នកស្នើទិញ)។

១៥០. សំអាងហេតុនៃសាលក្រម
Eng. grounds of judgment
Fr. motifs du jugement

ផ្នែកមួយនៃសាលក្រម ដែលបង្ហាញអំពីយោបល់របស់ចៅក្រម ក្នុងក្របខ័ណ្ឌនៃអង្គហេតុ ចំណុចវិវាទ និងច្បាប់ ដែលត្រូវយកមកអនុវត្តក្នុងដំណើរការវិនិច្ឆ័យសេចក្តី។

១៥១. ស្ថាប័ននីតិរដ្ឋបាល

Eng. administration of institution
Fr. institution de droit administratif

ស្ថាប័ន ដែលស្ថិតនៅក្រោមអានុភាពនៃច្បាប់រដ្ឋបាល។

១៥២. ហិតូបត្ថម្ភ

Eng. partial guardianship / curator
Fr. curatelle

ការគ្រប់គ្រងលើជន ដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។

១៥៣. ហិតូបត្ថម្ភកៈ

Eng. curator
Fr. curateur

ជន ដែលតុលាការចាត់តាំងឱ្យអនុវត្តហិតូបត្ថម្ភ។
(ម.ព. ហិតូបត្ថម្ភ)

១៥៤. អង្គសេចក្តី
Eng. merits
Fr. fond

ខ្លឹមសារជាមូលដ្ឋាននៃកម្ម វត្ថុរបស់បណ្តឹងរដ្ឋប្បវេណី។

១៥៥. អង្គហេតុ
Eng. fact
Fr. fait

រឿងហេតុ ដែលកើតឡើងនាំឱ្យមានបច្ច័យគតិយុត្តជាកំណត់។

១៥៦. អចលនវត្ថុ
Eng. immovable / real estate
Fr. immeuble

-ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជា អគារ សំណង់ ដំណាំ រុក្ខជាតិ។ល។
-សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិកលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយ ដែលច្បាប់បានកំណត់ថាជា អចលនវត្ថុ។

១៥៧. អត្តពន្ធភាពនៃសាលក្រម
Eng. self binding effect of judgment
Fr. dessaisissement du jugement

ចំណងផ្លូវច្បាប់ចំពោះតុលាការ ដែលបានចេញសាលក្រមរួចហើយមិនឱ្យលុប ឬកែប្រែសាលក្រមនោះ។

១៥៨. អត្តសញ្ញាណ
Eng. identity
Fr. identité

សញ្ញាណទាំងអស់នៃជនម្នាក់ៗ ឬវត្ថុនីមួយៗ ដែលជាគ្រឿងសម្គាល់កុំឱ្យភាន់ច្រឡំនឹងជនម្នាក់ទៀត ឬវត្ថុផ្សេងទៀត។
(មើលពាក្យនេះក្នុងសទ្ទានុក្រមនៃច្បាប់ភូមិបាល)

១៥៩. អត្ថិភាព
Eng. existence
Fr. existence

ភាពមាន ភាពកើតមានភាពស្ថិតនៅភាពនៃអ្វីៗ ដែលមាន(ពាក្យអត្ថិភាព ផ្ទុយនឹងពាក្យនត្ថិភាព)។

១៦០. អនីតិជន
Eng. minor
Fr. mineur

ជន ដែលមិនទាន់គ្រប់អាយុ តាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ឆ្នាំ។

១៦១. អនុតំណាង
Eng. secondary representative
Fr. sous-représentant

អ្នកដែលជ្រើសតាំងឡើង ដោយអ្នកតំណាង ហើយដែលមានសិទ្ធិ និងករណីយកិច្ច ចំពោះម្ចាស់សិទ្ធិ ដូចអ្នកតំណាងដែរ។

១៦២. អនុប្បទាន

Eng. transfer / assignment
Fr. cession

ការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទានយី ទៅឱ្យបុគ្គលម្នាក់ទៀត ដែលជាអនុប្បទានិក។ ឧ. អនុប្បទានភាគហ៊ុន (ការលក់ភាគហ៊ុន)។

១៦៣. អនុសារសាលក្រម

Eng. extract - abstract of original judgment
Fr. copie certifiée conforme du jugement / extrait du jugement / expédition du jugement

សេចក្តីចម្លងពីមូលសាលក្រម ដែលគ្មានបញ្ជាក់រូបមន្តអនុវត្ត។

១៦៤. អណុសារសាលក្រមស្ថាពរ

Eng. extract - abstract of original judgment
Fr. grosse / copie exécutoire du jugement

សេចក្តីចម្លងពីមូលសាលក្រមស្ថាពរ។ សេចក្តីដើមនៃការសម្រេចរបស់តុលាការនីមួយៗ ដែលមានរក្សាទុកនៅក្នុងបញ្ជីតុលាការ ហៅថា មូលសាលក្រម សេចក្តីចម្លងពីមូលសាលក្រមដែលគ្មានបញ្ជាក់រូបមន្តអនុវត្ត ហៅថា អនុសារសាលក្រម។

១៦៥. អនុសារសាលដីកាស្ថាពរ

Eng. extract - abstract of original judgment
Fr. copie exécutoire

សេចក្តីចម្លងពីមូលសាលដីកា។

១៦៦. អយ្យការ

Eng. public prosecution / prosecution office
Fr. parquet / ministère public

ស្ថាប័ន ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា និងការពារផលប្រយោជន៍សាធារណៈ។

១៦៧. អរូបទ្រព្យ

Eng. intangible property
Fr. bien incorporel

ទ្រព្យ ដែលគ្មានរូបជាក់ស្តែង តែត្រូវទទួលស្គាល់ថាជាទ្រព្យដែរ ដូចជា កម្មសិទ្ធិបញ្ញា ។ល។

១៦៨. អាគតដ្ឋាន

Eng. reference
Fr. référence

ទី ដែលដកស្រង់ ឬចម្លងយកមក។

១៦៩. អាជ្ញាយុកាល

Eng. prescription
Fr. prescription

អំឡុងពេលមួយ ដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ។

១៧០. អាជ្ញាសាលា
Eng. bailiff
Fr. huissier

មន្ត្រីជំនួយតុលាការទទួលបន្ទុកអនុវត្តកិច្ចការលក់ដោយបង្ខំ អនុវត្តសិទ្ធិប្រាតិភោគ អនុវត្តលក់ដោយបង្ខំ អនុវត្តសិទ្ធិប្រាតិភោគ អនុវត្តដោយបង្ខំ អនុវត្តការបញ្ជូនផ្នែកតាមការសម្រេចសេចក្តី ច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត។

១៧១. អាណាព្យាបាល
Eng. guardian
Fr. tutelle

ការគ្រប់គ្រងបីបាច់ថែរក្សាទ្រព្យសម្បត្តិ រូបកាយរបស់អនីតិជនដែលគ្មានអ្នកអនុវត្ត អំណាចមេបា ឬរបស់អសមត្ថជន។

១៧២. អានុភាព
Eng. effect
Fr. effet

ជនគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្តដូចជា កិច្ចសន្យា ច្បាប់ សេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរបស់រដ្ឋបាល ។ល។

១៧៣. អានុភាពប្រតិសកម្ម
Eng. retroactive effect
Fr. feet rétroactif

១-សកម្មភាពស្របតាមលក្ខខណ្ឌគតិយុត្ត ដែលមានឥទ្ធពលទៅលើសកម្មភាពពីអតីតភាព។
២-ឥទ្ធិពល នៃលក្ខខណ្ឌគតិយុត្ត ដែលមានទៅលើសកម្មភាពពីអតីតកាល។

១៧៤. អំពើអនីត្យានុកូល
Eng. illegal act
Fr. acte illégal

អំពើ ដែលបំពានដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬអតចេនា។

១៧៥. អ្នកជំនាញ
Eng. expert
Fr. expert

អ្នកឯកទេសដែលចៅក្រមសុំឱ្យផ្តល់មតិអំពីរឿងហេតុអ្វីមួយ ដែលតម្រូវឱ្យមានការយល់ដឹងបច្ចេកទេស និងការស្រាវជ្រាវយ៉ាងពេញលេញ។

១៧៦. អ្នកតំណាង
Eng. representative
Fr. représentant

បុគ្គលមានលក្ខណសម្បត្តិ ឬឋានៈតាមផ្លូវច្បាប់ ដែលបានទទួលសិទ្ធិតំណាង (ម.ព. សិទ្ធិតំណាង)។

១៧៧. អ្នកតំណាងដែលច្បាប់បានកំណត់
Eng. legal representative
Fr. représentant légal

បុគ្គល ដែលទទួលសិទ្ធិតំណាងកំណត់ដោយច្បាប់ដូចជា អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលជាដើម។
ឧ. អ្នកមានអំណាចមេបា អាចតំណាងឱ្យកូន ដែលជាអនីតិជន ចំពោះសកម្មភាពបណ្តឹង។

១៧៨. អ្នកតំណាងដោយអាណត្តិ

Eng. mandatory
Fr. mandataire

អ្នកដែលទទួលសិទ្ធិតំណាងដោយអាណត្តិ។
(ម.ព. សិទ្ធិតំណាងដោយអាណត្តិ)

១៧៩. អ្នកតំណាងពិសេស

Eng. special representative
Fr. représentant spécial /
représentant judiciaire

អ្នកដែលទទួលសិទ្ធិតំណាងតាមការចាត់តាំងរបស់តុលាការ។

១៨០. អ្នកអាណាព្យាបាល

Eng. guardian
Fr. tuteur

បុគ្គល ដែលអនុវត្តអាណាព្យាបាលភាព។

# សទ្ទានុក្រមនីតិវិធីរដ្ឋប្បវេណី

# ឧ ឯ

**១៨១. ឧបាទេសកម្ម**
Eng. subrogation
Fr. subrogation

ឋានៈមួយ ដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់។

**១៨១. ឯកសារចម្លងយថាភូត**
Eng. authentic copy
Fr. copie conforme

ឯកសារចម្លងមួយប្រភេទ ដែលចម្លងចេញពីឯកសារយថាភូត ដែលជាច្បាប់ដើមដែលត្រូវធ្វើឡើង ដោយបុគ្គលដែលមានអំណាចតាមបញ្ញត្តិនៃច្បាប់ ឬបទដ្ឋានគតិយុត្ត។

**១៨២. ឯកសារត្រៀម**
Eng. preparatory document
Fr. document préparatoire

ឯកសារ ដែលសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន ដែលភាគីយកទៅអះអាងចំពោះមុខតុលាការ។

**១៨៣. ឯកសិទ្ធិ**
Eng. privilege
Fr. privilège

សិទ្ធិ ដែលទទួលបាននូវការសងទ្រព្យ ដែលជាកម្មវត្ថុនៃឯកសិទ្ធិ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។